KB ធនាគារឯកទេស ខេប៊ី ដេហាន ម.ក
Daehan Specialized Bank Plc.

ជំពូក១: សេចក្តីផ្តើម | ជំពូក២: ចំណុចសំខាន់ៗនៅក្នុងឆ្នាំ២០១៩ | ជំពូក៣: របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម




# របាយការណ៍ប្រចាំឆ្នាំ ២០១៩


០២៣ ៩៩១ ៥៥៥
www.kdsb.com.kh
info@kdsb.com.kh
អគារលេខ ១ (វិមានការិយាល័យ អូរល) ជាន់ទី ២១ និង ២២ ផ្លូវ ៣៦០ សង្កាត់បឹងកេងកង ១ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ប្រទេសកម្ពុជា។

KB Daehan Specialized Bank Plc.


ស្កេនដើម្បីទាញយកកម្មវិធី
KDSB K-easy
App Store | Google Play

មាគ៌ាហិរញ្ញវត្ថុដ៏ល្អសម្រាប់អនាគតរបស់លោកអ្នក


K-easy
Your New Highway in Finance
ស្កេនដើម្បីទាញយកកម្មវិធី
KDSB
K-easy
Available on the App Store
GET IT ON Google Play

# មាតិកា

Your New Highway in Finance

## ជំពូកទី១ : សេចក្តីផ្តើម


- សាររបស់នាយកប្រតិបត្តិ ..... ០៣
- ព័ត៌មានធនាគារ ..... ០៤
- ព័ត៌មានម្ចាស់ភាគហ៊ុន (KB Financial Group) ..... ០៥-០៦
- ព័ត៌មានម្ចាស់ភាគហ៊ុន (KB Kookmin Card) ..... ០៧
- ព័ត៌មានម្ចាស់ភាគហ៊ុន (Indochina Bank) ..... ០៨
- ចក្ខុវិស័យ និងបេសកកម្ម ..... ០៩
- រចនាសម្ព័ន្ធគ្រប់គ្រង ..... ១០
- អភិបាលកិច្ចធនាគារ ..... ១១


## ជំពូកទី២ : ចំណុចសំខាន់ៗនៅក្នុងឆ្នាំ២០១៩


- ចំណុចសំខាន់ៗផ្នែកហិរញ្ញវត្ថុឆ្នាំ២០១៩ ..... ១៣
- ផលិតផល ..... ១៤
- សកម្មភាពទំនួលខុសត្រូវក្នុងសង្គមរបស់ធនាគារ ..... ១៥-១៧
- កម្មវិធីសុខុមាលភាព និងការលើកទឹកចិត្តបុគ្គលិក ..... ១៨-២០
- សកម្មភាពដទៃផ្សេងទៀត ..... ២១-២៣
- ពាក្យស្លោករបស់ធនាគារឯកទេស ខេប៊ី ដេហាន ម.ក ..... ២៤


## ជំពូកទី៣ : របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្ម



# មតិយោបល់របស់នាយកប្រតិបត្តិ

"សូមរីករាយជាមួយនឹងកំណើនដ៏ខ្លាំងក្លារបស់ ធនាគារឯកទេស ខេប៊ី ដេហាន"



ខ្ញុំសូមជូនពរដល់លោក-លោកស្រីឱ្យទទួលបានជោគជ័យត្រចះត្រចង់នៅគ្រប់កិច្ចការទាំងអស់ដែលលោក-លោកស្រីបំពេញ។

ខ្ញុំមានមោទនភាពក្រៃលែងក្នុងការផ្តល់របាយការណ៍នៅក្នុងឆ្នាំ២០១៩នេះ ទោះបីជានេះគ្រាន់តែជារបាយការណ៍ប្រចាំឆ្នាំលើកទីពីរក៏ពិតមែន ប៉ុន្តែធនាគារឯកទេស ខេប៊ី ដេហាន បានធ្វើការផ្សព្វផ្សាយរបាយការណ៍អំពីការអនុវត្តន៏ការងារពេញមួយរដូវកាលដំបូង។ខ្ញុំសូមសម្តែងនូវអំណរគុណដោយស្មោះ ចំពោះម្ចាស់ភាគហ៊ុនរបស់យើងសម្រាប់ការគាំទ្រ និងការលើកទឹកចិត្តយ៉ាងខ្លាំងរហូតសម្រេចបានសមិទ្ធផលដ៏ល្អប្រសើរសម្រាប់ធនាគារ។

ធនាគារឯកទេស ខេប៊ីដេហាន (តទៅហៅថា “ធនាគារ KDSB”) គឺជាសមាជិកមួយនៃក្រុមហ៊ុន KB Financial Group ដែលជាក្រុមហ៊ុនហិរញ្ញវត្ថុលំដាប់កំពូលនៅក្នុងប្រទេសកូរ៉េ និង បានវិវឌ្ឍខ្លួនក្លាយជាក្រុមហ៊ុនឈានមុខគេនៅក្នុងផ្នែកនវានុវត្តភាព និងសេវាកម្មនៅគ្រប់ផ្នែកទាំងអស់នៃវិស័យហិរញ្ញវត្ថុ រួមទាំងវិស័យធនាគារ មូលប័ត្រ និងប័ណ្ណឥណទានផងដែរ។

នៅក្នុងឆ្នាំ២០១៩ ធនាគារ KDSB បានសម្រេចនូវកំណើនយ៉ាងខ្ពស់គួរឱ្យកត់សម្គាល់ បើទោះបីខ្លួនជាធនាគារដែលបង្ហាញខ្លួនក្រោយគេនៅក្នុងទីផ្សារក្តី។ ធនាគារ KDSB បានក្លាយជាធនាគារដែលឈានមុខគេនៅក្នុងទីផ្សារផ្តល់ឥណទានសម្រាប់ទិញរថយន្តនៅក្នុងប្រទេសកម្ពុជា ដោយសម្រេចបានលទ្ធផលខ្ពស់តាមរយៈកំណើនយ៉ាងឆាប់រហ័ស។ ជាលទ្ធផលទំហំឥណទានបានកើនឡើងបីដងនៅដំណាច់ឆ្នាំ២០១៩ ចាប់តាំងពីដំណាច់ឆ្នាំ២០១៨ មក។

នៅពេលចូលទៅក្នុងទីផ្សារប្រទេសកម្ពុជា ធនាគារ KDSB ធ្លាប់មានបំណងជួយជ្រោមជ្រែងដល់អនាគតភ្លឺស្វាងសម្រាប់ប្រទេសកម្ពុជា តាមរយៈការបង្កើតនូវផលិតផលដែលមានភាពបត់បែន និងរហ័សទាន់ចិត្ត និងវប្បធម៌សាជីវកម្ម ហើយធនាគារ KDSB មានទំនុកចិត្តថា ឆ្នាំ២០១៨ គឺជាឆ្នាំដំបូងដែលបានសម្រេចគោលដៅនោះ។ នាពេលអនាគត យើងនឹងនៅតែបន្តកិច្ចដំណើរការ ក្នុងនាមជាកម្លាំងម៉ាស៊ីនជំរុញដ៏ខ្លាំងក្លាមួយសម្រាប់ការលូតលាស់យ៉ាងឆាប់រហ័សរបស់ប្រទេសកម្ពុជា តាមរយៈការផ្តល់នូវផលិតផលអាជីវកម្មថ្មីដូចជាប័ណ្ណឥណទាន និងកម្មវិធីឌីជីថលនានា។ល។

យើងដឹងថាការផ្តល់ហិរញ្ញប្បទានដើរតួនាទីសំខាន់ខ្លាំងប៉ុណ្ណាសម្រាប់អតិថិជនក្នុងការទិញទ្រព្យសកម្មរបស់ពួកគេ។ យើងនឹងខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពដើម្បីផ្តល់នូវកម្លាំងម៉ាស៊ីនជំរុញដ៏ខ្លាំងក្លាសម្រាប់ការរីកចម្រើនលូតលាស់នៃជីវិតរស់នៅ និងអាជីវកម្មរបស់អតិថិជនរបស់យើងនៅក្នុងប្រទេសកម្ពុជាដែលផ្អែកលើបទពិសោធន៏ និងចំណេះធ្វើរបស់យើងនៅក្នុងប្រទេសកូរ៉េ និងប្រទេសឡាវ។

សូមបន្តដំណើរលើ “មាគ៌ាហិរញ្ញវត្ថុដ៏ល្អសម្រាប់អនាគតរបស់លោកអ្នក” របស់ធនាគារឯកទេស ខេប៊ី ដេហាន ម.ក (KDSB)!!

សូមអរគុណ។

នាយកប្រតិបត្តិ
លោក **គង់ សាងយ៉ុន (Kong Sang-Yeon)**

# ការពិពណ៌នា សង្ខេបអំពីធនាគារ




ធនាគារ KDSB គឺជាក្រុមហ៊ុនបណ្តាក់ទុនរួមគ្នារវាងក្រុមហ៊ុន KB Kookmin Card Co., Ltd និងធនាគារ Indochina Bank ។ ក្រុមហ៊ុន KB Kookmin Card គឺជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន KB Financial Group។ ក្រុមហ៊ុន KB Financial Group គឺជាក្រុមហ៊ុនពហុផលិតផលហិរញ្ញវត្ថុឈានមុខគេដែលផ្តល់ជូននូវប្រភេទផលិតផល និងសេវាកម្មហិរញ្ញវត្ថុជាច្រើន ដែលក្រុមហ៊ុននេះគឺជាសមាជិកមួយរបស់ Dow Jones Sustainability Indices នៃទីផ្សារភាគហ៊ុនទីក្រុងញូវយ៉ក (NYSE)។ ធនាគារ Indochina Bank ធ្លាប់មានបទពិសោធន៏ជោគជ័យត្រចះត្រចង់នៅក្នុងការផ្តល់ឥណទានសម្រាប់ទិញរថយន្ត (Auto Finance) នៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ។ ដូច្នេះហើយទើបធនាគារ KDSB អាចផ្តល់សេវាកម្មយ៉ាងឆាប់រហ័ស និងមានភាពបត់បែនស្របតាមទីផ្សារឥណទានរបស់ប្រទេសកម្ពុជា ដើម្បីផ្តល់ជូននូវសង្គមហិរញ្ញវត្ថុដ៏ល្អប្រសើរមួយ។

| | |
|---|---|
| ឈ្មោះធនាគារ | ធនាគារឯកទេស ខេប៊ី ដេហាន ម.ក (“KDSB”) |
| ដើមទុនចុះបញ្ជី | ៤៣.៧៥០.០០០ ដុល្លារអាមេរិក |
| ម្ចាស់ភាគហ៊ុន | ក្រុមហ៊ុន KB Kookmin Card Co., Ltd ៩៥,៧%<br>ធនាគារ Indochina Bank Ltd. ៤,៣% |
| សាវតារ | ខែសីហា ឆ្នាំ២០០៨៖ បានបង្កើតឡើងជាធនាគារឯកទេស តូម៉ាតូ<br>ខែមីនា ឆ្នាំ២០១៨៖ បានផ្លាស់ប្តូរទៅជាធនាគារឯកទេស ខេប៊ី ដេហាន ម.ក |
| វិស័យអាជីវកម្ម | មានឯកទេសក្នុងផ្នែកឥណទានគេហដ្ឋាន និងការផ្តល់ឥណទានសម្រាប់ទិញរថយន្ត។ |
| ចំនួននិយោជិត | ១៤១ |
| ក្រុមហ៊ុនសវនកម្ម | ក្រុមហ៊ុន ប្រាយវ៉តធ័រ ហាវខូភើស៏ (ខេមបូឌា)<br>PriceWaterhouseCoopers (Cambodia) Ltd |
| ការិយាល័យកណ្តាល | អគារលេខ ១ (Oval Office Tower) ជាន់ទី២១ និងជាន់ទី២២ ផ្លូវលេខ៣៦០<br>សង្កាត់បឹងកេងកងទីមួយ ខណ្ឌបឹងកេងកង រាជធានីភ្នំពេញ ប្រទេសកម្ពុជា |

## ការពិពណ៌នាសង្ខេបអំពីម្ចាស់ភាគហ៊ុន

# KB Financial Group

ក្នុងនាមជាក្រុមហ៊ុនហិរញ្ញវត្ថុឈានមុខគេដែលមានមូលដ្ឋានអតិថិជនដ៏ធំបំផុត និងមានបណ្តាញសាខាក្រុមហ៊ុនយ៉ាងច្រើនបំផុតនៅក្នុងប្រទេសកូរ៉េ ក្រុមហ៊ុន KB Financial Group ប្តេជ្ញាចិត្តផ្តល់ជូនសេវាកម្មហិរញ្ញវត្ថុទូលំទូលាយគ្រប់បែបយ៉ាង ដែលពិតជាបំពេញតាមតម្រូវការជាច្រើនរបស់អតិថិជនយ៉ាងពិតប្រាកដ តាមរយៈកិច្ចសហការពីស្ថាប័នក្នុងចំណោមបុត្រសម្ព័ន្ធក្រុមហ៊ុនទាំង ១២។



ក្រុមហ៊ុន KB Financial Group និងបុត្រសម្ព័ន្ធរបស់ខ្លួន កំពុងសហការគ្នាយ៉ាងស្អិតរមួតក្នុងស្មារតីខិតខំប្រឹងប្រែងដោយឥតរាថយ ដើម្បីជំរុញឱ្យក្រុមហ៊ុន KB Financial Group មានការរីកចំរើនក្លាយទៅជាដៃគូហិរញ្ញវត្ថុជានិរន្តរ៍ដែលអតិថិជនរបស់ខ្លួនអាចពឹងផ្អែកបាន។ ក្រុមហ៊ុនធ្វើដូច្នេះទៅបានតាមរយៈឧត្តមភាពលើគូប្រកួតប្រជែងផ្សេងៗជាច្រើន ដែលកើតចេញមកពីចំណុចខ្លាំងផ្នែកមូលធនដ៏រឹងមាំ និងខ្សែបណ្តាញធំទូលាយរបស់ខ្លួន ក៏ដូចជាតាមរយៈជំនាញឯកទេសគ្រប់គ្រងហានិភ័យ និងកិច្ចដំណើរការដែលបានប្រមូលផ្តុំកាន់តែច្រើនឡើងៗតាមរយៈបទពិសោធន៍ជាច្រើនឆ្នាំកន្លងមកនេះ។ ដោយមានជំនឿយ៉ាងមុតមាំទៅលើការគ្រប់គ្រងដែលផ្តោតជាសំខាន់លើអតិថិជន និងបេសកកម្មក្រុមហ៊ុននៅក្នុង ‘ការផ្តល់សេវាហិរញ្ញវត្ថុធ្វើឱ្យមានការផ្លាស់ប្តូរជីវិតកាន់តែរីករាយ និងពិភពលោកកាន់តែល្អប្រសើរ’ ដូច្នេះយើងនឹងបន្តនូវនវានុវត្តភាពដោយឥតឈប់ឈរ ដោយផ្តល់នូវផលិតផល និងសេវាកម្មផ្សេងៗជាច្រើនតាមរយៈនវានុវត្តភាពដោយឥតប្រែប្រួលផ្អែកលើការសម្រេចចិត្តយ៉ាងឆាប់រហ័ស និងការអនុវត្តន៍ការងារប្រកបដោយភាពទន់ភ្លន់។ ក្រុមហ៊ុន KB Financial Group មានផែនការបន្តពង្រឹងគោលជំហរទីផ្សាររបស់យើងក្នុងនាមជា ក្រុមហ៊ុនហិរញ្ញវត្ថុឈានមុខគេប្រចាំប្រទេសកូរ៉េ។




### ៤២៨,៩ ប៊ីលានដុល្លារអាមេរិក

ស្ថាប័នហិរញ្ញវត្ថុធំជាងគេបំផុតនៅក្នុងប្រទេសកូរ៉េដែលមានទ្រព្យសកម្មសរុបចំនួន ៤២៨,៩ ប៊ីលានដុល្លារអាមេរិក (៦៥៤,៦ ប៊ីលានដុល្លារអាមេរិករាប់បញ្ចូលទាំងទ្រព្យសកម្មក្រោមការគ្រប់គ្រងនៃ AUM ផងដែរ)។



### ១.៦១៦ ការិយាល័យ

បណ្តាញអាជីវកម្មធំទូលាយបំផុត រួមទាំងសាខាធនាគារ KB Kookmin Bank ចំនួន ១.0៥៧ សាខា (ជាខ្សែបណ្តាញដ៏ធំបំផុតនៅក្នុងប្រទេសកូរ៉េ)

### មានចំណាត់ថ្នាក់លេខ១

លេខ ១ ក្នុងនាមជាអ្នកធានាលើការផ្តល់ឥណទាន និងការធានារ៉ាប់រងបំណុលមូលបត្រ (Lead Arranger & Book Runner) លេខ ១ ក្នុងចំណែកទីផ្សារនៅក្នុងវិស័យធនាគារតាមបណ្តាញអ៊ីនធឺណិត និងទូរសព្ទចល័តលេខ ១ រយៈពេល ១២ឆ្នាំជាប់គ្នានៅក្នុងការសិក្សាស្ទង់មតិ លើការពេញចិត្តរបស់អតិថិជនកូរ៉េ

### ៣៤,២ លាន

មូលដ្ឋានអតិថិជនរឹងមាំ (៦៦% នៃប្រជាជនកូរ៉េ)

* គិតមកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

# ការពិពណ៌នាសង្ខេបអំពីម្ចាស់ភាគហ៊ុន

## KB Financial Group បណ្ដាញជាសកល



ចក្រភពអង់គ្លេស
ធនាគារ KB Kookmin Bank ១

ចិន
ធនាគារ KB Kookmin Bank ៦
ធនាគារ KB Securities ១
ក្រុមហ៊ុន KB Insurance ២
ក្រុមហ៊ុន KB Asset Management ១

ជប៉ុន
ធនាគារ KB Kookmin Bank ១

សហរដ្ឋអាមេរិក
ធនាគារ KB Kookmin Bank ១
ធនាគារ KB Securities ១
ក្រុមហ៊ុន KB Insurance ៣

ឥណ្ឌា
ធនាគារ KB Kookmin Bank ១

### អាស៊ីអាគ្នេយ៍

កម្ពុជា
**ធនាគារឯកទេស ខេបី ដេហាន ម.ក**
(ក្រុមហ៊ុន KB Kookmin Card ១)
ធនាគារ KB Kookmin Bank ៦

មីយ៉ាន់ម៉ា
ធនាគារ KB Kookmin Bank ១៨
ក្រុមហ៊ុន KB Kookmin Card ១

ឡាវ
ក្រុមហ៊ុន KB capital ១

វៀតណាម
ធនាគារ KB Kookmin Bank ២
ធនាគារ KB Securities ៤
ក្រុមហ៊ុន KB Insurance ២
ក្រុមហ៊ុន KB Asset Management ១

សិង្ហបុរី
ក្រុមហ៊ុន KB Asset Management ១

ឥណ្ឌូណេស៊ី
ធនាគារ KB Kookmin Bank ១
ក្រុមហ៊ុន KB Insurance ៣

ហុងកុង
ធនាគារ KB Kookmin Bank ១
ក្រុមហ៊ុន KB Insurance ១

នូវែលសេឡង់
ធនាគារ KB Kookmin Bank ១

៦១ ខ្សែបណ្ដាញនៅក្រៅប្រទេស

ធនាគារ KB Kookmin Bank ៣៨, ក្រុមហ៊ុន KB Kookmin Card ២,
ធនាគារ KB Securities ៧, ក្រុមហ៊ុនធានារ៉ាប់រង KB Insurance ១០,
ក្រុមហ៊ុន KB Asset Management ៣, ក្រុមហ៊ុន KB Capital ១
* រួមទាំងការិយាល័យកណ្ដាល/សាខា/ការិយាល័យតំណាង

### ព័ត៌មានបច្ចុប្បន្ន

បានធ្វើលទ្ធកម្មភាគហ៊ុនចំនួន ៧០% ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដ៏ធំបំផុតមួយ។

## ការពិពណ៌នាសង្ខេបអំពីម្ចាស់ភាគហ៊ុន

# KB Kookmin Card

ក្រុមហ៊ុន KB Kookmin Card គឺជាក្រុមហ៊ុនផ្តល់ប័ណ្ណឥណទានឈានមុខគេ ដែលមានមូលដ្ឋានអតិថិជនប្រើប្រាស់សេវាជាប្រចាំចំនួន ១៩,៧លាននាក់ នៅប្រទេសកូរ៉េ។
យើងមានបំណងក្លាយខ្លួនជា "ដៃគូជីវិតរីករាយរបស់អ្នក" ដោយផ្តល់ជូននូវផលិតផលហិរញ្ញវត្ថុយ៉ាងល្អប្រសើរដល់អតិថិជន។

ជំរុញទឹកចិត្តតាមរយៈទេពកោសល្យលំដាប់ថ្នាក់ពិភពលោក និងនវានុវត្តភាពច្បាស់លាស់ ដើម្បីក្លាយខ្លួនជាដៃគូជីវិតរីករាយដ៏មានទំនុកចិត្តរបស់អ្នក។



| | |
|---|---|
| **កាលបរិច្ឆេទបង្កើតក្រុមហ៊ុន** | ខែកញ្ញា ឆ្នាំ១៩៨៧ |
| **វិស័យអាជីវកម្ម** | ប័ណ្ណឥណទាន ការផ្តល់ឥណទានហិរញ្ញវត្ថុ ការផ្តល់ឥណទានទិញរថយន្ត |
| **និយោជិត** | ១.៦០៩ |
| **ម្ចាស់ប័ណ្ណ** | ១៩,៧ លាន<br>(៤០% នៃប្រជាជនកូរ៉េ) |
| **ពាណិជ្ជករ** | ២,៧ លាន |
| **ទំហំប្រតិបត្តិការទឹកប្រាក់** | ១៤៧,៩ ទ្រីលានវ៉ុន |
| **ទ្រព្យសរុប** | ២៣,០ ទ្រីលានវ៉ុន |
| **ប្រាក់ចំណេញប្រតិបត្តិការ** | ៣១៦,៦ ទ្រីលានវ៉ុន |

កំណត់សម្គាល់៖ គិតមកត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

# KB Kookmin Card

បានឈ្នះជ័យលាភី Presidential Award នៅក្នុងកម្មវិធី Labor-Management Culture Awards ឆ្នាំ២០១៩។

## ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

បានទទួលជ័យលាភីនៅក្នុងកម្មវិធី National Service Awards ឆ្នាំ២០១៩ ក្នុងវិស័យប័ណ្ណឥណទានតាមកម្មវិធីទូរសព្ទចល័តពីវិទ្យាស្ថានសម្រាប់ការសិក្សាគោលនយោបាយឧស្សាហកម្ម (Institute for Industrial Policy Studies)

បានឈ្នះជ័យលាភី Prime Minister's Citation នៅក្នុង "ខួបលើកទី13នៃទិវាប្រឆាំងនឹងការសម្អាតប្រាក់ (Anti-Money Laundering Day)" អង្គភាពស៊ើបការណ៍ហិរញ្ញវត្ថុ (Financial Intelligence Unit)

## ការវាយតម្លៃកម្រិត A2 (មានស្ថេរភាព) ពីក្រុមហ៊ុន MOODY's

បានទទួលការវាយតម្លៃកម្រិត 'A2' និងការផ្តល់មតិយោបល់ថា "មានស្ថេរភាព" ដែលជាកម្រិតវាយតម្លៃខ្ពស់ជាងគេបំផុតក្នុងចំណោមក្រុមហ៊ុនឯកទេសផ្តល់ឥណទាននៅក្នុងប្រទេសកូរ៉េ ពីការវាយតម្លៃរបស់ក្រុមហ៊ុន Moody's។

## ប័ណ្ណឥណពន្ធ M/S ចំណាត់ថ្នាក់លេខ ១

រយៈពេល ៩ ឆ្នាំជាប់ៗគ្នា



ទឹកប្រាក់ ៣៤,៩ ទ្រីលានវ៉ុននៅក្នុងទំហំប្រតិបត្តិការប័ណ្ណឥណពន្ធដែលឈរក្នុងទីផ្សារមានចំណាត់ថ្នាក់លេខ ១ នៅក្នុងប្រទេសកូរ៉េ។

## ការពង្រីកខ្លួនជាសាកល

ក្រុមហ៊ុន *PT Finansia Multi Finance*
ឯកទេសក្នុងអាជីវកម្មផ្តល់ឥណទានហិរញ្ញវត្ថុ នៃប្រទេសឥណ្ឌូណេស៊ី (ទឹកប្រាក់ប្រមាណ ៨១ លានដុល្លារអាមេរិក)



# ការពិពណ៌នាសង្ខេប អំពីម្ចាស់ភាគហ៊ុន

ធនាគារ Indochina Bank ត្រូវបានបង្កើតឡើងនៅក្នុងសាធារណរដ្ឋប្រជាធិបតេយ្យ ប្រជាមានិតឡាវ នៅក្នុងឆ្នាំ២០០៨។
ម្ចាស់ភាគហ៊ុនរបស់ធនាគារនេះ មានក្រុមហ៊ុនដែលមានកេរ្តិ៍ឈ្មោះល្បី និងរូបវន្តបុគ្គលដែលមានប្រវត្តិអាជីវកម្មរឹងមាំ និងមានស្ថេរភាព គឺ លោក Oh Sei Young និងក្រុមហ៊ុន LVMC Investment Ltd.។

ធនាគារនេះ មានបណ្តាញសាខាចំនួន ១៣ ដែលគ្របដណ្តប់នៅគ្រប់ខេត្តទាំងអស់។ បទពិសោធន៍ និងចំណេះធ្វើរបស់ធនាគារនេះ នឹងត្រូវផ្សព្វផ្សាយដល់ធនាគារឯកទេស ខេប៊ី ដេហាន ម.ក។




## ទីស្នាក់ការកណ្តាល

អាសយដ្ឋាន៖ អគារ ខូឡាវ, ១១៦, ផ្លូវសឹង្ហ ២៣,
ប្រអប់សំបុត្រលេខ ៦០២៩
ទូរស័ព្ទ (+៨៥៦-២១) ៤៥៥ ០០០-៣
ទូរសារ (+៨៥៦-២១) ៤៥៥ ១១១

## ចក្ខុវិស័យរបស់ធនាគារ

"ដើម្បីក្លាយខ្លួនជាធនាគារឯកជនចំណាត់ថ្នាក់លេខ ១ នៅក្នុងប្រទេសឡាវ ពាក់ព័ន្ធនឹងការរីកចម្រើនអាជីវកម្ម សេវាកម្មអតិថិជន ផលិតផល និងប្រាក់ចំណេញ ក៏ដូចជាការផ្សព្វផ្សាយទីផ្សារ និងបន្តការលើកកម្ពស់សេវាកម្មរបស់យើង ដើម្បីបំពេញភាពពេញចិត្តរបស់អតិថិជនក្នុងកម្រិតខ្ពស់បំផុត ។"

# ចក្ខុវិស័យ និងបេសកកម្ម

ចក្ខុវិស័យរបស់ធនាគារឯកទេស ខេប៊ី ដេហាន គឺក្លាយខ្លួនជាធនាគារឯកទេសតាមរយៈបទពិសោធន៍ជោគជ័យពីប្រទេសកូរ៉េ។ បេសកកម្មរបស់ធនាគារឯកទេស ខេប៊ី ដេហាន ម.ក គឺធ្វើឱ្យមនុស្សមានអារម្មណ៍រំភើបរីករាយតាមរយៈការផ្តល់សេវាកម្មឆាប់រហ័ស និងមានភាពបត់បែន ដូចគ្នាទៅនឹងលទ្ធភាពក្នុងការបើកបររថយន្តទំនើប (supercar) នៅលើផ្លូវហាយវេយ៉ាងដូច្នោះដែរ។

## បេសកកម្ម

ការផ្តល់សេវាកម្មហិរញ្ញវត្ថុ ធ្វើឱ្យមានការផ្លាស់ប្តូរ - ជីវិតកាន់តែរីករាយ និងពិភពលោកកាន់តែល្អប្រសើរ
យើងផ្តោតលើការផ្តល់សេវាហិរញ្ញវត្ថុដែលនាំមកនូវសេចក្តីសុខ
និងសុភមង្គលដល់អតិថិជន និងសង្គម។

## ចក្ខុវិស័យ

ជំរុញទឹកចិត្តតាមរយៈទេពកោសល្យលំដាប់ពិភពលោក និងនវានុវត្តភាពច្បាស់លាស់
ដើម្បីក្លាយខ្លួនជា ដៃគូជីវិតរីករាយ ដ៏មានទំនុកចិត្តរបស់អ្នក
គោលដៅរបស់យើងគឺក្លាយខ្លួនជាក្រុមហ៊ុនហិរញ្ញវត្ថុយូរអង្វែងមួយតាមរយៈ
នវានុវត្តភាពឈានមុខគេដែលផ្លាស់ប្តូរគំរូហិរញ្ញវត្ថុដោយអ្នកជំនាញវិជ្ជាជីវៈល្អបំផុតរបស់យើង។

## គុណតម្លៃស្នូល៖

- **ការផ្តោតលើអតិថិជន៖** អត្ថប្រយោជន៍សម្រាប់អតិថិជន និងការផ្តល់អាទិភាពដល់ពួកគេនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តរបស់យើង។
- **ជំនាញឯកទេស៖** យើងខិតខំប្រឹងប្រែងឥតឈប់ឈរដើម្បីអភិវឌ្ឍន៍សមត្ថភាពឈានមុខគេក្នុងផ្នែកឧស្សាហកម្ម។
- **នវានុវត្តភាព៖** យើងលើកកម្ពស់ការគិតបែបច្នៃប្រឌិត និងជំរុញឱ្យមានគំនិតផ្តួចផ្តើមលើផ្នែកទីផ្សារដំបូងគេ ដើម្បីរៀបចំអនាគត នៃឧស្សាហកម្ម សេវាហិរញ្ញវត្ថុសាជាថ្មីឡើងវិញ។
- **ការជឿទុកចិត្ត និងសុចរិតភាព៖** ក្នុងនាមជាអ្នកផ្តល់សេវាហិរញ្ញវត្ថុមួយយើងតែង គោរពតាមស្តង់ដាកម្រិតខ្ពស់ បំផុតនៃក្រមសីលធម៌វិជ្ជាជីវៈ ដោយធ្វើសកម្មភាពប្រកបដោយភាពស្មោះត្រង់ និងដោយសុចរិតភាព។
- **ការរីកលូតលាស់ទាំងអស់គ្នា៖** តាមរយៈការរីកលូតលាស់ទាំងអស់គ្នា ជាមួយនឹងអតិថិជនយើងមានគោលបំណង ចូលរួមចំណែកដល់ការរីកចម្រើនជឿនលឿននៃសង្គម។



# រចនាសម្ព័ន្ធអង្គភាព

គិតមកត្រឹមថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០



# អភិបាលកិច្ចសាជីវកម្ម

### រចនាសម្ព័ន្ធ និងសមាសភាពក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល នៃធនាគារឯកទេស ខេប៊ី ដេហាន ម.ក មានសមាសភាពចំនួន ០៤ រូប រួមបញ្ចូលទាំងអភិបាលឯករាជ្យចំនួនមួយរូបផងដែរ ដែលពួកគេទាំងអស់សុទ្ធតែទទួលបានការតែងតាំងនៅក្នុងមហាសន្និបាតម្ចាស់ហ៊ុន។
អភិបាលទាំងអស់ គឺសុទ្ធតែជាអ្នកមានជំនាញឯកទេសនៅក្នុងវិស័យរបស់ពួកគេម្នាក់ៗ ជាមួយនឹងបទពិសោធន៍ទូលំទូលាយនៅក្នុងវិស័យនានា ដូចជាផ្នែកអាជីវកម្ម និងការគ្រប់គ្រងធនាគារ និងផ្នែកច្បាប់ជាដើម។ ប្រធានក្រុមប្រឹក្សាភិបាល ត្រូវបានបោះឆ្នោតជ្រើសតាំងដោយក្រុមប្រឹក្សាភិបាល។

## ក្រុមប្រឹក្សាភិបាល

| | |
|---|---|
| លោក Kang Nam Che | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Kong Sang Yeon | សមាជិក (អភិបាលប្រតិបត្តិ) |
| លោក Bounheang Souphida | សមាជិក (អភិបាលមិនប្រតិបត្តិ) |
| លោក Kim Hyong Kun | សមាជិក (អភិបាលឯករាជ្យ) |

## គណៈកម្មការ

### គណៈកម្មការសវនកម្ម

គណៈកម្មការសវនកម្ម ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាលនៅថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៨ ដើម្បីជួយដល់ក្រុមប្រឹក្សាភិបាលនៅក្នុងការអនុវត្តន៍ទំនួលខុសត្រូវផ្នែកអភិបាលកិច្ច និងការត្រួតពិនិត្យ។

| | |
|---|---|
| លោក Kim Hyong Kun | ប្រធានគណៈកម្មការ (អភិបាលឯករាជ្យ) |
| លោក Lee Sang In | សមាជិក |
| លោក អ៊ុំ ចន្ថន | សមាជិក |

### គណៈកម្មការតែងតាំង និងផ្តល់តម្លៃការ

គណៈកម្មការនេះ ត្រូវបង្កើតប្រព័ន្ធវាយតម្លៃ និងផ្តល់សំណងដោយយុត្តិធម៌ ស្របទៅតាមការបំពេញការងាររបស់គណៈគ្រប់គ្រង និងបុគ្គលិក និងមជ្ឈដ្ឋាននៃការផ្តល់ប្រាក់រង្វាន់ជាទូទៅ។

| | |
|---|---|
| លោក Kim Hyong Kun | ប្រធានគណៈកម្មការ (អភិបាលឯករាជ្យ) |
| លោក Kong Sang Yeon | សមាជិក |
| លោក Lee Sang In | សមាជិក |

### គណៈកម្មការគ្រប់គ្រងហានិភ័យ

គណៈកម្មការនេះ ដើរតួនាទីជាស្ថាប័នធ្វើការសម្រេចខ្ពស់ជាងគេបំផុត។ គណៈកម្មការនេះ បង្កើត និងអនុម័តលើយុទ្ធសាស្ត្រគ្រប់គ្រងហានិភ័យ និងគោលការណ៍ណែនាំនានាដើម្បីកំណត់ វាស់វែង ត្រួតពិនិត្យ និងគ្រប់គ្រងរាល់ហានិភ័យទាំងអស់ដែលកើតចេញពីប្រតិបត្តិការសាច់ប្រាក់នានា របស់ធនាគារឱ្យបានទាន់ពេលវេលា។

| | |
|---|---|
| លោក Kong Sang Yeon | ប្រធានគណៈកម្មការ |
| លោក Lee Sang In | សមាជិក |
| លោក Park Jong Deok | សមាជិក |

# ចំណុចសំខាន់ៗ នៅក្នុងឆ្នាំ ២០១៩



KB Daehan Specialized Bank Plc.

# ការគូសបញ្ជាក់អំពីស្ថានភាពហិរញ្ញវត្ថុចម្បងៗ ឆ្នាំ២០១៩

ធនាគារឯកទេស ខេប៊ី ដេហាន ម.ក បានបង្ហាញពីការអនុវត្តន៍ការងារជាច្រើនតាមរយៈកំណើននៃទ្រព្យសកម្មសរុប ២២០% សម្រាប់ឆ្នាំ២០១៩ និង ៣១១% នៅក្នុងឆ្នាំ២០១៨។ កំណើនជាចម្បងនៃទ្រព្យសកម្មសរុបនេះ គឺភាគច្រើនបានមកពីការកើនឡើងនៃការផ្តល់ឥណទានដែលមានចំនួន ១៩៧% នៅក្នុងឆ្នាំ២០១៩ និង ៥៥៦% នៅក្នុងឆ្នាំ២០១៨។

ជាលទ្ធផល ធនាគារឯកទេស ខេប៊ី ដេហាន ម.ក បានទទួលជ័យលាភីជា "ធនាគារដែលរីកចម្រើនយ៉ាងឆាប់រហ័សបំផុតសម្រាប់ការផ្តល់ឥណទាននៅកម្ពុជា ឆ្នាំ២០១៩"។

## ចំណូលសុទ្ធ

(គិតជាពាន់ដុល្លារ)




## ទ្រព្យសកម្មសរុប

(គិតជាលានដុល្លារ)




## អនុបាតឥណទាន

(គិតជា %)




## ទ្រព្យសកម្មឥណទាន

(គិតជាពាន់ដុល្លារ)




ដំណាលគ្នានឹងកំណើនយ៉ាងឆាប់រហ័សនេះ ធនាគារ KDSB ក៏ផ្តោតការយកចិត្តទុកដាក់យ៉ាងខ្លាំងផងដែរលើកិច្ចដំណើរការ និងគោលនយោបាយ គ្រប់គ្រងហានិភ័យ។

ធនាគារឯកទេស ខេប៊ី ដេហាន ម.ក ក៏សម្រេចបានផលលើសបរិមាណ (អតិរេក) ក្នុងអំឡុងឆ្នាំប្រតិបត្តិការពេញមួយឆ្នាំដំបូង។




**ធនាគារដែលរីកចម្រើនយ៉ាងឆាប់រហ័សបំផុត សម្រាប់ការផ្តល់ឥណទាននៅកម្ពុជា ឆ្នាំ២០១៩**

# ផលិតផល

## ការផ្តល់ឥណទានសម្រាប់ទិញរថយន្ត

តាមរយៈទស្សនាទានថ្មីនៃឥណទានសម្រាប់ទិញរថយន្ត នៅក្នុងឆ្នាំ២០១៩ ធនាគារ KDSB បានផ្តល់ឥណទានយ៉ាងជោគជ័យដល់អតិថិជនដែលមានបំណងចង់បានរថយន្តតាមក្តីស្រមៃរបស់ពួកគេ។ ក្នុងនាមជាដៃគូចម្បងនៃក្រុមហ៊ុន Ssangyong Motor និងជាអ្នកឧបត្ថម្ភធំនៃកម្មវិធីចេញផ្សាយរថយន្តស៊េរីថ្មីម៉ាក Ford Adventure និង Mazda ផងនោះ ធនាគារ KDSB តែងឈរនៅជាប់ជាមួយដៃគូរបស់យើងជានិច្ច។
















## ឥណទានទូទៅ

នៅពេលណាដែលអតិថិជនមានបំណងទទួលយកឥណទានណាមួយដោយដាក់ប័ណ្ណកម្មសិទ្ធិមានតម្លៃសម្រាប់ជាទ្រព្យធានា នោះធនាគារ KDSB អាចផ្តល់នូវដំណោះស្រាយដ៏ល្អជូនដល់អតិថិជន សម្រាប់អាជីវកម្ម និងគ្រួសាររបស់ពួកគេ។





# សកម្មភាព CSR

## យុទ្ធនាការកាត់បន្ថយថង់ផ្លាស្ទិក

ជាមួយនឹងស្មារតីគិតគូរថែរក្សាសោភណភាព និងបរិស្ថានសង្គម ធនាគារ KDSB បានបង្កើតនូវថង់បរិស្ថាន (eco-bags) រាប់ពាន់ថង់ ហើយចែកចាយថង់ទាំងនោះដោយឥតគិតថ្លៃដល់អ្នកទិញទំនិញ និងអ្នកលក់ទៅតាមផ្សារក្នុងមូលដ្ឋានជាច្រើនកន្លែងក្នុងរាជធានីភ្នំពេញ ដូចជានៅផ្សារកណ្តាល ផ្សារធំថ្មី ផ្សារដេប៉ូ និងផ្សារអូរឡាំពិក។ ការចែកថង់បរិស្ថានដោយឥតគិតថ្លៃនេះ បានធ្វើឡើងរយៈពេលបីថ្ងៃជាប់ៗគ្នាដោយក្រុមបុគ្គលិកជាច្រើននាក់របស់ធនាគារ KDSB ដើម្បីចូលរួមចំណែកដល់ការការពារបរិស្ថាន និងការកាត់បន្ថយការប្រើប្រាស់ថង់ផ្លាស្ទិកនៅក្នុងប្រទេសកម្ពុជា។





## ប្រអប់កាដូចែកជូនដល់អ្នកធាក់ស៊ីក្លូ

ស៊ីក្លូ ដែលជាត្រីចក្រយានមានកង់បី បន្តស្ថិតនៅជាផ្នែកមួយនៃមធ្យោបាយដឹកជញ្ជូនសម្រាប់ប្រជាពលរដ្ឋនៅរាជធានីភ្នំពេញ។ ប៉ុន្តែអំឡុងរដូវប្រាំងដែលមានសីតុណ្ហភាពក្តៅខ្លាំង ជាពិសេសកម្តៅពេលថ្ងៃត្រង់ អ្នកធាក់ស៊ីក្លូជួបប្រទះការលំបាកខ្លះៗនៅក្នុងការដឹកជញ្ជូនអតិថិជនរបស់ពួកគេពីផ្ទះមួយទៅផ្ទះមួយ។ ដើម្បីកាត់បន្ថយភាពលំបាកប្រចាំថ្ងៃរបស់ពួកគេ ធនាគារ KDSB បានបរិច្ចាគកញ្ចប់អំណោយដែលរួមមានកេសភេសជ្ជៈជំនួយសុខភាពដែលមានតុល្យភាពសារធាតុដែក ទឹកបរិសុទ្ធ និងអាវយឺត។ សកម្មភាពនេះ ត្រូវបានធ្វើឡើងដោយមានការអនុញ្ញាតពីអាជ្ញាធរផ្សារអូរឫស្សី។






# សកម្មភាព CSR

## កម្មវិធីលើកកម្ពស់ស្នាដៃគំនូរខ្មែរ

ធនាគារ KDSB បានចាប់ផ្តើមកម្មវិធីលើកកម្ពស់ស្នាដៃគំនូរខ្មែរនៅក្នុងឆ្នាំ២០១៩ ដើម្បីលើកកម្ពស់គំនូរផាត់ពណ៌នៅក្នុងប្រទេសកម្ពុជា។ ដើម្បីសម្រេចគោលបំណងនេះ ធនាគារបានទិញគំនូរពីគ្រូគំនូរអាជីពពីររូប និងបានបង្កើតនូវការប្រកួតប្រជែងគំនូរ។ កុមារចំនួន ២៩ នាក់ (ជាអ្នកប្រកួត) ត្រូវបានជ្រើសរើសសម្រាប់ការប្រកួតគំនូរនេះ ចំណែកឯសមាជិកគ្រួសារម្នាក់ ឬ ពីរនាក់របស់កុមារនីមួយៗត្រូវបានអនុញ្ញាតឱ្យចូលរួម។






គ្រូគំនូរទាំងពីររូប បានទទួលការអញ្ជើញមកផ្តល់ការណែនាំដោយសង្ខេបអំពីគំនូរផាត់ពណ៌នៅក្នុងប្រទេសកម្ពុជាជូនដល់អ្នកប្រកួត និងធ្វើជាគណៈកម្មការកាត់សេចក្តីលើការប្រកួតនោះ។ កុមារនឹងកែលម្អបំណិននៃការស្រមើស្រមៃ ភាពច្នៃប្រឌិត និងការបង្កើតថ្មីរបស់ពួកគេឱ្យកាន់តែល្អប្រសើរឡើងនៅក្នុងបទពិសោធន៍នៃការគូររូបភាពផ្ទាល់ខ្លួនរបស់ពួកគេ។ ផ្ទាំងគំនូរផាត់ពណ៌ និងគំនូររូបភាពរបស់អ្នកឈ្នះជ័យលាភីកំពូល ៣ រូបដែលបានទិញយក នឹងត្រូវយកទៅដាក់តាំងនៅការិយាល័យកណ្តាលរបស់ធនាគារសម្រាប់ការតាំងបង្ហាញ។ កម្មវិធីនេះគ្រោងនឹងរៀបចំឡើងជារៀងរាល់ឆ្នាំ។






# សកម្មភាព CSR

## កម្មវិធីគាំទ្រផលិតផលកែច្នៃឡើងវិញ

(កិច្ចសហការជាមួយសិប្បកម្មឈ្លាសវៃ)






សិប្បកម្មឈ្លាសវៃ Smart Craft គឺជាសហគ្រាសសង្គម និងបរិស្ថានមួយដែលផ្តល់ឱកាសការងារដល់អ្នកដែលមានពិការភាព និងជួយឱ្យបរិស្ថានស្អាត។ ធនាគារ KDSB បានសហការជាមួយសិប្បកម្មឈ្លាសវៃ និងបានយល់ព្រមបន្តគាំទ្រ និងទិញផលិតផលកែច្នៃឡើងវិញពីសិប្បកម្មឈ្លាសវៃទៅតាមគម្រោងដែលបានកំណត់។

ធនាគារ KDSB និងសិប្បកម្មឈ្លាសវៃ នឹងរួមគ្នាបង្កើតផលិតផលបែបច្នៃប្រឌិត និងនាំមុខក្នុងការលើកទឹកចិត្តក្នុងការការពារបរិស្ថាន និងការកែច្នៃឡើងវិញនៅក្នុងប្រទេសកម្ពុជា។

## ការដាក់កញ្ចក់ចំណាំងផ្លាតនៅតាមកែងផ្លូវ

គ្រោះថ្នាក់ចរាចរណ៍ គឺជាបុព្វហេតុចម្បងនៃការស្លាប់នៅក្នុងប្រទេសកម្ពុជា។ ដើម្បីជួយកាត់បន្ថយគ្រោះថ្នាក់ចរាចរណ៍នៅក្នុងប្រទេសកម្ពុជា ធនាគារ KDSB បានតម្លើងកញ្ចក់ចរាចរណ៍នៅតាមកែងផ្លូវតូចចង្អៀតនៅក្នុងរាជធានីភ្នំពេញ ចាប់តាំងពីឆ្នាំ២០១៨ មកម្ល៉េះ។ ធនាគារបានប្តេជ្ញាចិត្តជួយកាត់បន្ថយបញ្ហាចរាចរណ៍ តាមរយៈការបន្តថែរក្សាកញ្ចក់ចំណាំងផ្លាតតាមកែងផ្លូវដែលបានតម្លើងរួច និងបន្តតម្លើងកញ្ចក់ចរាចរណ៍នៅតាមដងផ្លូវតូចចង្អៀតផ្សេងទៀត។



# កម្មវិធីសុខុមាលភាព និងការលើកទឹកចិត្តបុគ្គលិក




ការចែករំលែកក្តីស្រលាញ់ និងភាពរីករាយនៅថ្ងៃទិវានៃក្តីស្រលាញ់

បន្ថែមពីលើការផ្តោតការយកចិត្តទុកដាក់ខ្ពស់ ចំពោះសុខុមាលភាពបុគ្គលិកតាមរយៈការផ្តល់បរិយាកាសការងារប្រកបដោយផាសុកភាព ធនាគារ KDSB ក៏ផ្តោតផងដែរទៅលើការបង្កើតបរិយាកាសរីករាយនៅកន្លែងការងារ និងការបង្ហាញការកោតសរសើរចំពោះបុគ្គលិកគ្រប់រូប។ នៅខែកុម្ភៈ ធនាគារ KDSB បានរៀបចំអបអរកម្មវិធីទិវានៃក្តីស្រលាញ់តូចមួយដើម្បីបង្កភាពរីករាយភ្ញាក់ផ្អើលទៅដល់បុគ្គលិកទាំងអស់ ដោយផ្តល់ឱ្យពួកគេនូវអំណោយបន្តិចបន្តួចសម្រាប់ថ្ងៃបុណ្យនៃក្តីស្រលាញ់នោះដោយមានភ្ជាប់មកជាមួយនូវលិខិតថ្លែងអំណរគុណចំពោះស្មារតីលះបង់ និងការបំពេញការងារយ៉ាងល្អរបស់ពួកគេ និងអរគុណចំពោះការបន្តបំពេញភារកិច្ចរបស់ពួកគេជាមួយនឹង ធនាគារ KDSB។

# ការប្រគំតន្ត្រីខ្នាតតូច

ធនាគារ KDSB បានរៀបចំការប្រគំតន្ត្រីខ្នាតតូចនៅខាងក្នុងបរិវេណធនាគារដើម្បីអបអរសាទរ និងផ្តល់រង្វាន់ដល់បុគ្គលិកឆ្នើមសម្រាប់សមិទ្ធផលការងាររបស់ពួកគេ នៅត្រីមាសទីមួយនៃឆ្នាំ ២០១៩។ ក្នុងគោលបំណងបង្កើតភាពសប្បាយរីករាយនិងមិនអាចបំភ្លេចបាននោះ ធនាគារ KDSB បានអញ្ជើញកញ្ញា រ៉ាប៊ី (ជាតារាចម្រៀងដ៏ល្បីប្រចាំផលិតកម្មថោន) និងក្រុមរាំរបស់នាងដើម្បីសម្តែងនៅក្នុងពិធីជប់លៀង។ កម្មវិធីនេះ ក៏ផ្តោតផងដែរទៅដល់ការជំរុញលើកទឹកចិត្តក្នុងចំណោមបុគ្គលិកនៅការិយាល័យហើយអនុញ្ញាតឱ្យបុគ្គលិកទទួលទានអាហារពេលល្ងាចយ៉ាងរីករាយជាមួយនឹងតន្ត្រីប្រគំផ្ទាល់នៅនឹងកន្លែង។



# កម្មវិធីសុខុមាលភាព និង ការលើកទឹកចិត្តបុគ្គលិក




## សិក្ខាសាលាក្រៅប្រទេស

នៅខែឧសភា ឆ្នាំ២០១៩ ធនាគារ KDSB បានផ្តល់ការបណ្តុះបណ្តាលលើកិច្ចដំណើរការអនុវត្តន៏ការងារ (Bench-learning Training) និងសិក្ខាសាលាក្រៅប្រទេសសម្រាប់បុគ្គលិកឆ្នើមរបស់ធនាគារ KDSB ក្នុងឆ្នាំ២០១៨។ ការបណ្តុះបណ្តាលលើកិច្ចដំណើរការអនុវត្តន៏ការងារ ត្រូវបានធ្វើឡើងនៅក្រុមហ៊ុន KB Financial Group នៅទីក្រុងសេអ៊ូល ប្រទេសកូរ៉េខាងត្បូង។

សិក្ខាសាលារយៈពេលមួយសប្តាហ៍នេះ បានអនុញ្ញាតឱ្យអ្នកចូលរួមឆ្លងកាត់កម្មវិធីបណ្តុះបណ្តាលពិសេសស្តីពីការគ្រប់គ្រងហានិភ័យ ការផ្តល់ឥណទានសម្រាប់ទិញរថយន្ត ឌីជីថលនីយកម្ម និងទីផ្សារប័ណ្ណឥណទាន។ ម្យ៉ាងទៀត វាក៏ផ្តល់ឱកាសផងដែរសម្រាប់បុគ្គលិកឆ្នើម ដើម្បីទទួលបានបទពិសោធន៍នៅក្នុងវប្បធម៌កូរ៉េ និងទៅទស្សនាទីកន្លែងល្បីៗជាច្រើនដូចជារាជវាំង Gyungbok សារមន្ទីរ K-Pop មជ្ឈមណ្ឌលលក់ទំនិញ DongDaeMoon និងធ្វើដំណើរកម្សាន្តទៅទីតាំងសំខាន់ៗនៃក្រុមហ៊ុន KB Koomin Card។ ធនាគារ KDSB នៅតែរក្សាទុកកម្មវិធីនេះ ដើម្បីលើកទឹកចិត្តបុគ្គលិក និងធ្វើការសិក្សាស្វែងយល់អំពីបទពិសោធន៍នេះនៅទីតាំងការិយាល័យកណ្តាល។





# កម្មវិធីអត្តពលកម្ម



កម្មវិធីអត្តពលកម្ម គឺជាកម្មវិធីនៅខាងក្រៅដែលបានបង្កើតឡើងស្របគ្នាទៅនឹងកម្មវិធីប្រគល់រង្វាន់ប្រចាំត្រីមាសទីពីរ។ បន្ថែមពីលើពិធីប្រគល់រង្វាន់សម្រាប់បុគ្គលិកឆ្នើមនៅក្នុងត្រីមាសទីពីរ ធនាគារ KDSB បានផ្តល់ជូនបុគ្គលិកទាំងអស់នូវឱកាសដើម្បីឱ្យពួកគេចូលរួមទៅក្នុងកម្មវិធីអត្តពលកម្មនេះ។ នេះជាពេលវេលាដ៏ល្អសម្រាប់និយោជិត និងគណៈគ្រប់គ្រង ដើម្បីបន្ធូរបន្ថយភាពតានតឹង និងទទួលបានបទពិសោធន៍ហាត់ប្រាណសម្រាប់សុខភាពផ្លូវកាយ និងផ្លូវចិត្ត។ ទឹកមុខញញឹម និងសំឡេងសើចក្អាកក្អាយរបស់និយោជិត និងគណៈគ្រប់គ្រង បានកើតឡើងនៅពេលពួកគេរីករាយលេងកីឡា និងល្បែងកម្សាន្ត ការទទួលទានអាហារ និងការរាំកម្សាន្តចាប់ពីពេលរសៀលរហូតដល់ពេលយប់។

# រង្វាន់ប្រចាំត្រីមាស



រង្វាន់ប្រចាំត្រីមាស ត្រូវបានរៀបចំឡើង ដើម្បីផ្តល់ភាពរីករាយដល់ បុគ្គលិកឆ្នើម ប្រចាំត្រីមាសដែលបានខិតខំបំពេញការងារ និងចូលរួមចំណែកជួយជ្រោមជ្រែងដល់ធនាគារក៏ដូចជាដើម្បីបង្កើតបរិយាកាសសប្បាយរីករាយដល់និយោជិតទាំងអស់ផងដែរ។ កម្មវិធីនេះបានអនុញ្ញាតឱ្យបុគ្គលិកជជែកគ្នាលេងដោយរីករាយ និងកសាងនូវទំនាក់ទំនងក្នុងក្រុមការងារ។

# វគ្គសិក្សាភាសាកូរ៉េ



ធនាគារ KDSB បានបើកថ្នាក់ភាសាកូរ៉េសម្រាប់និយោជិត ដែលមានបំណងទទួលបានចំណេះដឹងបន្ថែមសម្រាប់ការអភិវឌ្ឍអនាគតរបស់ពួកគេ។ វគ្គសិក្សានេះផ្តល់ឱកាសដល់និយោជិតក្នុងការសិក្សាភាសាថ្មីមួយ និងទទួលបានចំណេះដឹងបន្ថែមអំពីវប្បធម៌របស់កូរ៉េ ដែលជាខ្លាអាស៊ីមួយ និងជាមាតុប្រទេសរបស់ក្រុមហ៊ុនមេនៃធនាគារនេះ។

# សកម្មភាពផ្សេងៗ

## ពិធីអបអរសាទរខួបលើកទី១ និងពិធីជប់លៀងថ្លែងអំណរគុណ

ធនាគារ KDSB បានប្រារព្ធពិធីអបអរសាទរជាផ្លូវការគម្រប់ខួបលើកទី១ នៅថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៩ ។














នេះបង្ហាញឱ្យឃើញពីកំណើនលូតលាស់របស់ខ្លួន ក្រោយរយៈពេលមួយឆ្នាំនៃកិច្ចដំណើរការនៅក្នុងវិស័យហិរញ្ញវត្ថុកម្ពុជា។ ដើម្បីបង្ហាញការដឹងគុណដោយស្មោះចំពោះភាគីពាក់ព័ន្ធទាំងអស់សម្រាប់ការគាំទ្ររបស់ពួកគេចំពោះកំណើនលូតលាស់របស់ធនាគារ ដូច្នេះធនាគារ KDSB បានគោរពអញ្ជើញអតិថិជន ដៃគូអាជីវកម្ម និងគ្រប់និយោជិត និងក្រុមគ្រួសាររបស់ពួកគេទាំងអស់ឱ្យមកចូលរួមនៅក្នុងពិធីជប់លៀងដែលមានអាហារប៊ូហ្វេពេលល្ងាច និងការសម្តែងសិល្បៈ (កម្មវិធី NABA)។ បន្ថែមពីលើនេះ និយោជិតម្នាក់ៗបានទទួលកាដូដោយមានភ្ជាប់មកជាមួយនូវលិខិតអញ្ជើញមួយច្បាប់ដោយមានសំណេរដោយដៃរបស់ក្រុមគណៈគ្រប់គ្រងកំពូលដែលសរសេរថ្លែងអំណរគុណ និងការកោតសរសើរផ្សេងៗចំពោះតួនាទី និងការរួមចំណែករបស់និយោជិតម្នាក់ៗចំពោះធនាគារ។



















# រង្វាន់ប្រចាំឆ្នាំ២០១៩

ក្រៅពីរង្វាន់ប្រចាំត្រីមាស ធនាគារ KDSB បានរៀបចំរង្វាន់ប្រចាំឆ្នាំ ជារៀងរាល់ឆ្នាំ ដើម្បីអបអរសាទរដល់ការបំពេញការងារក្នុងឆ្នាំនីមួយៗ។ ដូច្នេះពិធីប្រគល់រង្វាន់ឆ្នាំ២០១៩ ក៏ត្រូវបានប្រារព្ធធ្វើឡើងដើម្បីរីករាយស្វាគមន៍ចំពោះស្នាដៃសម្រេចបានរបស់និយោជិតទាំងអស់ ក៏ដូចជាធនាគារផងដែរនៅក្នុងឆ្នាំ២០១៩ និងអបអរសាទរដល់បុគ្គលិកឆ្នើមនៅក្នុងឆ្នាំនោះដែរ។

ព្រឹត្តិការណ៍នេះបានផ្តល់ឱ្យនិយោជិតទទួលបានការធ្វើបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅ ការកម្សាន្ត និងភាពរីករាយតាមរយៈសកម្មភាពផ្សេងៗ ដូចជាការរៀបចំអាហារពេលល្ងាច រង្វាន់បុគ្គលិកឆ្នើម រង្វាន់ពិសេស (អ្នកចូលរួមបុរស / ស្ត្រីដែលស្រស់ស្អាតបំផុត និងមានរូបភាពទាក់ទាញបំផុត) កម្មវិធីបង្ហាញទេពកោសល្យ និងការចាប់ឆ្នោតផ្សងសំណាង។ ម្យ៉ាងទៀត ការធ្វើបទបង្ហាញអំពីផែនការអាជីវកម្មឆ្នាំ២០២០ក៏ត្រូវបានរាប់បញ្ចូលទៅក្នុងព្រឹត្តិការណ៍នេះដែរ។

តាមរយៈព្រឹត្តិការណ៍នេះ គ្រប់និយោជិតទាំងអស់សុទ្ធតែមានឱកាសក្នុងការជួបប្រជុំ និងធ្វើបដិសណ្ឋារកិច្ចយ៉ាងកក់ក្តៅជាមួយអគ្គនាយកក្រុមហ៊ុន KB Kookmin Card គឺលោក Lee Dong Cheol ។ ស្នាមញញឹមប្រិមប្រិយបង្ហាញឱ្យឃើញនៅលើទឹកមុខរបស់និយោជិតម្នាក់ៗនៅក្នុងការជួបជុំគ្រួសាររបស់ធនាគារ KDSB ដ៏ធំនេះ។







# ផែនការឆ្នាំ២០២០

## ការបើកសម្ពោធសាខា

នៅក្នុងខែកុម្ភៈ ឆ្នាំ២០២០ នៅខណ្ឌសែនសុខ ធនាគារឯកទេស ខេប៊ី ដេហាន ម.ក បានបើកសម្ពោធជាផ្លូវការនូវសាខាទីមួយរបស់ខ្លួន។ មនុស្សសំខាន់ជាច្រើន បានចូលរួម និងរីករាយជាមួយនឹងសាខាថ្មីនេះ។ ធនាគារ KDSB មានផែនការបើកសាខា ច្រើនបន្ថែមទៀតដើម្បីផ្តល់ភាពងាយស្រួលក្នុងការជួបជាមួយអតិថិជន។




អគារលេខ ៦៩ និង ៧១ ផ្លូវលេខ ១០០៣ ភូមិប៉ាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ

023 992 555 www.kdsb.com.kh info@kdsb.com.kh

## អាជីវកម្មប័ណ្ណឥណទាន

ក្នុងនាមជាបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុន KB Kookmin card ដែលជាក្រុមហ៊ុនប័ណ្ណឥណទានដ៏សំខាន់ជាងគេបំផុតនៅក្នុងប្រទេសកូរ៉េ ក្រុមហ៊ុននេះនឹងពង្រីកអាជីវកម្ម សម្រាប់អាជីវកម្មប័ណ្ណឥណទានថ្មីប្លែកតាមប្រព័ន្ធកម្មវិធីក្នុងទូរសព្ទចល័ត។ វាកំពុងតែបង្ហាញវិសាលភាពដ៏ធំធេងរបស់ខ្លួននៅក្នុងប្រទេសកម្ពុជា។




មាគ៌ាហិរញ្ញវត្ថុដ៏ល្អសម្រាប់អនាគតរបស់លោកអ្នក
023 991 555
www.facebook.com/kbdaehan
info@kdsb.com.kh

ធនាគារឯកទេស ខេប៊ី ដេហាន ម.ក

# របាយការណ៍ហិរញ្ញវត្ថុ

## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩



ធនាគារឯកទេស ខេប៊ី ដេហាន ម.ក

របាយការណ៍ហិរញ្ញវត្ថុ

សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

# មាតិកា ទំព័រ


**របាយការណ៍ក្រុមប្រឹក្សាភិបាល** ........ ១-៤

**របាយការណ៍សវនករឯករាជ្យ** ........ ៥-៨

**របាយការណ៍ហិរញ្ញវត្ថុ៖**

>របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ ........ ៩

>របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ ........ ១០

>របាយការណ៍បម្រែបម្រួលមូលធន ........ ១១

>របាយការណ៍លំហូរសាច់ប្រាក់ ........ ១២

>កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ ........ ១៣-១០៩




## របាយការណ៍ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលសូមដាក់បង្ហាញរបាយការណ៍របស់ខ្លួន និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក (ហៅកាត់ថា “ធនាគារ”) សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩។

## អំពីធនាគារ

ធនាគារបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨ ក្រោម វិញ្ញាបនបត្រចុះបញ្ជីលេខ Co.000២0២១៨ ចេញដោយក្រសួងពាណិជ្ជកម្ម។ ធនាគារបានទទួលអាជ្ញាប័ណ្ណជាធនាគារឯកទេសពីធនាគារជាតិ នៃ កម្ពុជា (ហៅកាត់ថា “ធនាគារកណ្ដាល”) នៅថ្ងៃទី១0 ខែកក្កដា ឆ្នាំ២០០៨ ដើម្បីធ្វើប្រតិបត្តិការជាធនាគារឯកទេស។

នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ ធនាគារកណ្ដាលបានអនុម័តឱ្យធនាគារប្ដូរនាមករណ៍របស់ខ្លួនពី “ធនាគារ ឯកទេស តូម៉ាតូ” ទៅជា “ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក”។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅជាន់ទី២១ និង២២ នៃអគារលេខ ១ ផ្លូវលេខ ៣៦0 សង្កាត់បឹងកេងកង ១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

## លទ្ធផលហិរញ្ញវត្ថុ

លទ្ធផលហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ធនាគារ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ត្រូវបានដាក់បង្ហាញនៅលើរបាយការណ៍លទ្ធផល ទំព័រទី១០។

## ដើមទុន

ក្នុងអំឡុងឆ្នាំនេះ ធនាគារបានបង្កើនដើមទុនរបស់ខ្លួនពី ១៨.៧៥០.000 ដុល្លារអាមេរិក ដល់ ៤៣.៧៥០.000 ដុល្លារអាមេរិក តាមរយៈការដាក់ដើមទុនបន្ថែម ចំនួន ២៥.000.000 ដុល្លារអាមេរិក នៅក្នុងឆ្នាំ។

## សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារ គឺការផ្ដល់កម្ចីទិញយានយន្ត និងឥណទានទូទៅ ដល់សហគ្រាសធុនតូច និងមធ្យមដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

### ហានិភ័យឥណទាន និងសង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋាន សមរម្យ ពាក់ព័ន្ធទៅនឹងការជម្រះឥណទាន និងបុរេប្រទានអាក្រក់ចេញពីបញ្ជី ឬការធ្វើសំវិធានធនការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់ឥណទាន និងបុរេប្រទានអាក្រក់ទាំងអស់ដែលបានដឹង ត្រូវបានជម្រះចេញពីបញ្ជី និងបានកត់ត្រាសំវិធានធនសម្រាប់ការខាតបង់ពេញលេញ ចំពោះឥណទាន និងបុរេប្រទានអាក្រក់ និងសង្ស័យ។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលនាំឱ្យចំនួនឥណទាន និងបុរេប្រទាន អាក្រក់ដែលបានជម្រះចេញពីបញ្ជី ឬចំនួនសំវិធានធនសម្រាប់ការខាតបង់ដែលបណ្តាលមកពីការថយចុះតម្លៃ ក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ មានតម្លៃមិនគ្រប់គ្រាន់នោះទេ។

### ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមរម្យដើម្បីបញ្ជាក់ថា ទ្រព្យសកម្មទាំងឡាយដែលទំនងជាមិនអាចទទួលស្គាល់បានជាក់ស្តែងក្នុងអាជីវកម្មធម្មតា ទៅតាមតម្លៃក្នុងបញ្ជីគណនេយ្យរបស់ធនាគារ ត្រូវបានកត់ត្រាបន្ថយឱ្យនៅស្មើនឹងចំនួនដែលរំពឹងថានឹងអាចទទួលស្គាល់បានជាក់ស្តែង។

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ និងផ្អែកតាមកម្រិតនៃការយល់ដឹង ក្រុមប្រឹក្សាភិបាលពុំបានដឹងពីកាលៈទេសៈណាមួយ ដែលអាចបណ្តាលឱ្យតម្លៃទ្រព្យសកម្មក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ពុំត្រឹមត្រូវជាសារវន្តនោះទេ។

### បំណុលយថាភាព និងបំណុលផ្សេងៗ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ៖

ក. មិនមានបន្ទុកណាមួយលើទ្រព្យសកម្មរបស់ធនាគារ ដែលបានកើតឡើងដោយសារការដាក់វាបញ្ចាំ សម្រាប់ការធានាបំណុលរបស់បុគ្គលណាម្នាក់ឡើយ ចាប់តាំងពីដំណាច់ឆ្នាំហិរញ្ញវត្ថុមក និង

ខ. មិនមានបំណុលយថាភាពណាមួយរបស់ធនាគារ ដែលបានកើតឡើងចាប់តាំងពីដំណាច់ឆ្នាំមក ក្រៅពីបំណុលផ្សេងៗ នៅក្នុងដំណើរការអាជីវកម្មធម្មតានោះទេ។

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល ក្រៅពីបំណុលយថាហេតុផ្សេងៗ ពុំមានបំណុលយថាភាព ឬបំណុលផ្សេងៗរបស់ធនាគារ បានក្លាយជាការបង្ខំឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងរយៈពេល១២ខែបន្ទាប់ពីដំណាច់ឆ្នាំដែលនឹង ឬអាចនឹងមានផលប៉ះពាល់ជាសារវន្តដល់លទ្ធភាពរបស់ធនាគារ ក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅថ្ងៃកំណត់សងនោះទេ។

### ការប្រែប្រួលកាលៈទេសៈ

គិតត្រឹមកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីកាលៈទេសៈណាមួយ ដែលមិនបានរែករៀកនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ដែលអាចបណ្តាលឱ្យចំនួនទឹកប្រាក់ដែលបានដាក់បង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុ មានភាពមិនត្រឹមត្រូវជាសារវន្តនោះទេ។

## ប្រតិបត្តិការមិនប្រក្រតី

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល លទ្ធផលប្រតិបត្តិការរបស់ធនាគារក្នុងឆ្នាំនេះ មិនបានទទួលរងនូវផលប៉ះពាល់ជាសារវន្តពីខ្ទង់គណនី ប្រតិបត្តិការ ឬព្រឹត្តិការណ៍មិនប្រក្រតីណាមួយឡើយ។ តាមយោបល់របស់ក្រុមប្រឹក្សាភិបាល តាំងពីដំណាច់ឆ្នាំ រហូតមកទល់នឹងកាលបរិច្ឆេទនៃរបាយការណ៍នេះ មិនមានខ្ទង់គណនី ប្រតិបត្តិការ ឬ ព្រឹត្តិការណ៍ខុសប្រក្រតីណាមួយ ដែលអាចជះឥទ្ធិពលជាសារវន្តដល់លទ្ធផលហិរញ្ញវត្ថុរបស់ធនាគារ ក្នុងឆ្នាំដែលរបាយការណ៍នេះត្រូវបានធ្វើឡើងនោះទេ។

## ក្រុមប្រឹក្សាភិបាល

សមាជិកក្រុមប្រឹក្សាភិបាលដែលបានបម្រើការងារក្នុងអំឡុងឆ្នាំ និងរហូតមកដល់កាលបរិច្ឆេទនៃរបាយការណ៍នេះ មានរាយនាមដូចខាងក្រោម៖

| | |
|---|---|
| លោក Kang Nam Che | ប្រធានក្រុមប្រឹក្សាភិបាល |
| លោក Kong Sang Yeon | អភិបាល (អភិបាលប្រតិបត្តិ) |
| លោក Bounheng Souphida | អភិបាល (អភិបាលមិនប្រតិបត្តិ) បានតែងតាំងនៅថ្ងៃទី១៩ ខែសីហា ឆ្នាំ២០១៩ |
| លោក Kim Hyong Kun | អភិបាល (អភិបាលឯករាជ្យ) |

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវក្នុងការបញ្ជាក់ថារបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើង និងបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់របស់ធនាគារ សម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃ កម្ពុជា (ហៅកាត់ថា "CIFRS")។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ ក្រុមប្រឹក្សាភិបាលត្រូវ ៖

១. អនុវត្តគោលការណ៍គណនេយ្យសមស្រប ដែលគាំទ្រដោយការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនេះឱ្យមានសង្គតិភាព។

២. អនុវត្តតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មានរបស់ CIFRS ហើយប្រសិនបើមានការប្រាសចាកណាមួយក្នុងការបង្ហាញឱ្យមានភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនោះត្រូវបានលាតត្រដាងពន្យល់ និងកំណត់ចំនួនទឹកប្រាក់ឱ្យបានត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

៣. រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ និងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងប្រកបដោយប្រសិទ្ធភាព។

៤. រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយផ្អែកលើមូលដ្ឋាននិរន្តរភាពនៃដំណើរការអាជីវកម្ម លើកលែងតែមានករណីសន្មតសមរម្យថា ធនាគារនឹងមិនអាចបន្តកិច្ចប្រតិបត្តិការអាជីវកម្មនៅពេលអនាគតដ៏ខ្លី និង

៥. គ្រប់គ្រង និងដឹកនាំធនាគារឱ្យមានប្រសិទ្ធភាព តាមរយៈការសម្រេចចិត្តជាសារវន្តទាំងអស់ដែលជះឥទ្ធិពលដល់ប្រតិបត្តិការនិងលទ្ធផលរបស់ធនាគារ ហើយត្រូវធានាថាផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថាធនាគារបានអនុវត្តតាមតម្រូវការខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

## ការអនុម័តរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលបានអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ព្រមទាំងកំណត់សម្គាល់ទាំងឡាយដែលភ្ជាប់មកជាមួយ ដែលបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់នៃស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាម CIFRS ។

ចុះហត្ថលេខាដោយយោងទៅតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល។

ព្រះរាជាណាចក្រកម្ពុជា
KB Daehan Specialized Bank Plc.
KINGDOM OF CAMBODIA

**លោក Kong Sang Yeon**
**នាយកប្រតិបត្តិ**

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២០

## របាយការណ៍សវនករឯករាជ្យ
## ជូនភាគទុនិក ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក

### មតិយោបល់របស់យើងខ្ញុំ

តាមមតិយោបល់របស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុរបស់ ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក (ហៅកាត់ថា "ធនាគារ") បង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ អំពីស្ថានភាពហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ និងលទ្ធផលហិរញ្ញវត្ថុ ព្រមទាំងលំហូរសាច់ប្រាក់របស់ធនាគារសម្រាប់ដំណាច់ឆ្នាំ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃ កម្ពុជា (ហៅកាត់ថា "CIFRS")។

### របាយការណ៍ដែលយើងខ្ញុំបានធ្វើសវនកម្ម

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ រួមមាន៖

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩
- របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍បម្រែបម្រួលមូលធនសម្រាប់ដំណាច់ឆ្នាំ
- របាយការណ៍លំហូរសាច់ប្រាក់សម្រាប់ដំណាច់ឆ្នាំ និង
- កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

### មូលដ្ឋាននៃមតិយោបល់របស់យើងខ្ញុំ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារអន្តរជាតិ ស្តីពីសវនកម្មនៃកម្ពុជា (ហៅកាត់ថា "ស្តង់ដារសវនកម្ម")។ ការទទួលខុសត្រូវរបស់យើងខ្ញុំដែលអនុលោមទៅតាមស្តង់ដារទាំងនោះ ត្រូវបានពណ៌នាបន្ថែមទៀតនៅក្នុងកថាខណ្ឌ "ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ" នៅក្នុងរបាយការណ៍សវនកម្មរបស់យើងខ្ញុំ។

យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងខ្ញុំបានទទួល មានភាពគ្រប់គ្រាន់ និងសមហេតុផល ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។

### ឯករាជ្យ

យើងខ្ញុំមានឯករាជ្យពីធនាគារ ដែលអនុលោមទៅតាមក្រមសីលធម៌សម្រាប់គណនេយ្យករវិជ្ជាជីវៈ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារក្រមសីលធម៌អន្តរជាតិ (ហៅកាត់ថា "ក្រមសីលធម៌អន្តរជាតិ") និងអនុលោមទៅតាមក្រមសីលធម៌របស់វិទ្យាស្ថានគណនេយ្យករជំនាញ និងសវនករកម្ពុជា (ហៅកាត់ថា "ក្រមសីលធម៌ វគសក")។ យើងខ្ញុំបានបំពេញកាតព្វកិច្ចក្នុងការទទួលខុសត្រូវផ្នែកក្រមសីលធម៌ផ្សេងៗទៀត ដែលកំណត់ដោយ ក្រមសីលធម៌អន្តរជាតិ និង ក្រមសីលធម៌ វគសក។

## ព័ត៌មានផ្សេងៗ

គណៈគ្រប់គ្រងទទួលខុសត្រូវចំពោះព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗដែលយើងខ្ញុំបានទទួលបាននាកាលបរិច្ឆេទរបាយការណ៍សវនកម្មនេះ រួមមាន របាយការណ៍ក្រុមប្រឹក្សាភិបាល និងព័ត៌មានហិរញ្ញវត្ថុបន្ថែម និងការលាតត្រដាងព័ត៌មានទៅតាមតម្រូវការរបស់ ធនាគារជាតិ នៃ កម្ពុជា ប៉ុន្តែព័ត៌មានទាំងនេះមិនមែនជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍សវនកររបស់យើងខ្ញុំទេ។

មតិយោបល់របស់យើងខ្ញុំចំពោះរបាយការណ៍ហិរញ្ញវត្ថុ ពុំបានគ្របដណ្តប់ទៅលើព័ត៌មានផ្សេងៗនោះទេ ហើយយើងខ្ញុំមិនធ្វើការធានាអះអាងចំពោះព័ត៌មានទាំងនោះទេ។

ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំទៅលើរបាយការណ៍ហិរញ្ញវត្ថុ យើងខ្ញុំទទួលខុសត្រូវក្នុងការអានព័ត៌មានផ្សេងៗដែលបានរៀបរាប់ខាងលើ ដើម្បីពិចារណាថាតើព័ត៌មានផ្សេងៗទាំងនោះមានភាពផ្ទុយគ្នាជាសារវន្តពីរបាយការណ៍ហិរញ្ញវត្ថុ ឬផ្ទុយពីការយល់ដឹងរបស់យើងខ្ញុំផ្អែកលើលទ្ធផលនៃការធ្វើសវនកម្ម ឬមានការរាយការណ៍ពីកំហុសឆ្គងជាសារវន្តដែលបានកើតឡើងឬទេ។

ផ្អែកទៅលើការងារដែលយើងខ្ញុំបានបំពេញ ទៅលើព័ត៌មានផ្សេងៗដែលយើងខ្ញុំទទួលបានមុនកាលបរិច្ឆេទនៃរបាយការណ៍សវនករនេះ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តដែលកើតចេញពីព័ត៌មានផ្សេងៗទាំងនេះ យើងខ្ញុំត្រូវរាយការណ៍ពីអង្គហេតុនៃកំហុសឆ្គងទាំងនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ចំពោះបញ្ហានេះទេ។

## ការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង និងអ្នកដែលទទួលបន្ទុកលើអភិបាលកិច្ចចំពោះរបាយការណ៍ហិរញ្ញវត្ថុ

គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការរៀបចំ និងបង្ហាញរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ ដោយអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និងស្តង់ដារគណនេយ្យកម្ពុជា និងទទួលខុសត្រូវលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលគណៈគ្រប់គ្រងកំណត់ថាមានភាពចាំបាច់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ឱ្យចៀសផុតពីការរាយការណ៍ខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ គណៈគ្រប់គ្រងទទួលខុសត្រូវក្នុងការវាយតម្លៃអំពីលទ្ធភាពរបស់ធនាគារក្នុងការបន្តនិរន្តរភាពអាជីវកម្ម ការលាតត្រដាងព័ត៌មានដែលពាក់ព័ន្ធ ក៏ដូចជាបញ្ហាផ្សេងៗដែលទាក់ទិនទៅនឹងនិរន្តរភាពអាជីវកម្ម ដោយប្រើមូលដ្ឋានគណនេយ្យសម្រាប់និរន្តរភាពអាជីវកម្ម លើកលែងតែគណៈគ្រប់គ្រងគ្រោងនឹងបិទអាជីវកម្មរបស់ធនាគារ ឬបញ្ឈប់ប្រតិបត្តិការ ដោយមិនមានជម្រើសណាផ្សេងប្រកបដោយភាពប្រាកដប្រជាណាមួយ។

អ្នកដែលទទួលបន្ទុកលើអភិបាលកិច្ច ត្រូវមានការទទួលខុសត្រូវក្នុងការត្រួតពិនិត្យដំណើរការនៃការរាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ។

## ការទទួលខុសត្រូវរបស់សវនករ ក្នុងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺស្វែងរកអំណះអំណាងដែលសមហេតុផល ថារបាយការណ៍ហិរញ្ញវត្ថុទាំងមូលពុំមានការរាយការណ៍ខុសជាសារវន្តដែលបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ និងចេញរបាយការណ៍សវនកម្មដែលមានមតិយោបល់របស់យើងខ្ញុំ។ ការអះអាងដែលសមហេតុផលគឺជាការអះអាងក្នុងកម្រិតខ្ពស់ ប៉ុន្តែវាមិនមែនជាការធានាថាសវនកម្មដែលបានធ្វើឡើងដោយអនុលោមទៅតាមស្តង់ដារសវនកម្ម តែងតែរកឃើញជានិច្ចនូវការរាយការណ៍ខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការរាយការណ៍ខុសអាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយវាត្រូវបានចាត់ទុកថាមានលក្ខណៈជាសារវន្ត ប្រសិនបើការរាយការណ៍ខុសនីមួយៗ ឬការរាយការណ៍ខុសសរុប អាចត្រូវបានរំពឹងថាវាជះឥទ្ធិពលលើមូលដ្ឋាននៃការសម្រេចចិត្តផ្នែកសេដ្ឋកិច្ច របស់អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ផ្នែកមួយនៃការធ្វើសវនកម្មដែលអនុលោមទៅតាមស្តង់ដារសវនកម្ម តម្រូវឱ្យយើងខ្ញុំប្រើប្រាស់ការវិនិច្ឆ័យ និងរក្សាការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈក្នុងពេលបំពេញការងារសវនកម្មរបស់យើងខ្ញុំ ហើយយើងខ្ញុំ៖

- កំណត់ និងវាយតម្លៃហានិភ័យនៃភាពខុសជាសារវន្តនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលអាចបណ្តាលមកពីការក្លែងបន្លំ ឬកំហុសឆ្គងផ្សេងៗ ដោយតាក់តែងនីតិវិធីសវនកម្ម និងធ្វើសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យ ទាំងនោះ និងស្វែងរកភ័ស្តុតាងសវនកម្មគ្រប់គ្រាន់ និងសមស្រប ដើម្បីធ្វើជាមូលដ្ឋានសម្រាប់ការបញ្ចេញមតិយោបល់របស់យើងខ្ញុំ។ ហានិភ័យដែលបណ្តាលមកពីការរកមិនឃើញកំហុសជាសារវន្តពីការក្លែងបន្លំ វាមានទំហំធំជាងហានិភ័យដែលបណ្តាលមកពីកំហុសឆ្គងអចេតនា។ ការក្លែងបន្លំរួមមាន ការសមគំនិត ការក្លែងបន្លំឯកសារ ការលុបបំបាត់ដោយចេតនា ការបង្ហាញខុស ឬការរំលងប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង។
- ស្វែងយល់អំពីប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងដែលពាក់ព័ន្ធទៅនឹងសវនកម្ម ដើម្បីតាក់តែងនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនបញ្ចេញមតិយោបល់របស់យើងខ្ញុំទៅលើប្រសិទ្ធភាពនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងរបស់ធនាគារទេ។
- វាយតម្លៃអំពីភាពសមស្របនៃគោលការណ៍គណនេយ្យដែលបានប្រើប្រាស់ ភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការលាតត្រដាងពាក់ព័ន្ធ ដែលគណៈគ្រប់គ្រងបានធ្វើឡើង។
- សន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋានគណនេយ្យនិរន្តរភាពអាជីវកម្ម របស់គណៈគ្រប់គ្រង អាស្រ័យទៅលើភ័ស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន ថាតើវាមានភាពមិនច្បាស់លាស់ជាសារវន្តដែលបានកើតឡើងកម្រិតណាពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានា អាចបណ្តាលឱ្យមានការសង្ស័យជាដុំកំភួន ទៅលើលទ្ធភាពរបស់ធនាគារ ក្នុងការបន្តនិរន្តរភាពអាជីវកម្មរបស់ខ្លួនដែរឬទេ។ ប្រសិនយើងខ្ញុំសន្និដ្ឋានថា វាមានភាពមិនច្បាស់លាស់ជាសារវន្តបានកើតឡើង នោះយើងខ្ញុំត្រូវធ្វើការបង្ហាញនៅក្នុងរបាយការណ៍សវនកម្ម ដើម្បីទាញចំណាប់អារម្មណ៍អ្នកប្រើប្រាស់របាយការណ៍ហិរញ្ញវត្ថុ ចំពោះការលាតត្រដាងព័ត៌មាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ ឬប្រសិនបើការលាតត្រដាងនោះនៅមិនទាន់គ្រប់គ្រាន់ទៀត យើងខ្ញុំត្រូវធ្វើការកែប្រែមតិយោបល់របស់យើងខ្ញុំ។ សេចក្តីសន្និដ្ឋានសរុបរបស់យើងខ្ញុំ អាស្រ័យទៅលើភ័ស្តុតាងសវនកម្មដែលយើងខ្ញុំទទួលបាន រហូតដល់ថ្ងៃចុះហត្ថលេខាលើរបាយការណ៍សវនកម្មនេះ។ ទោះជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនានាក្នុងពេលអនាគត អាចបណ្តាលឱ្យធនាគារឈប់បន្តនិរន្តរភាពអាជីវកម្ម។

pwc

- វាយតម្លៃការបង្ហាញទូទៅ រចនាសម្ព័ន្ធ និងខ្លឹមសារក្នុងរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងការលាតត្រដាងព័ត៌មានផ្សេងៗ និងកំណត់ថារបាយការណ៍ហិរញ្ញវត្ថុបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិការណ៍ជាក់ស្តែង ដែលអាចធ្វើឱ្យមានការបង្ហាញត្រឹមត្រូវ។

យើងខ្ញុំបានរាយការណ៍ជូនអ្នកដែលទទួលបន្ទុកអភិបាលកិច្ចនូវបញ្ហាផ្សេងៗដូចជា ទំហំការងារ និងពេលវេលាសវនកម្ម ព្រមទាំងបញ្ហាសវនកម្មសំខាន់ៗ រួមទាំងរាយការណ៍ពីភាពខ្វះខាតជាសារវន្តនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលយើងខ្ញុំបានរកឃើញក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំ។

**ខ. ក្រុមហ៊ុន** PricewaterhouseCoopers ( Cambodia ) Ltd.

**គុយ លីម**

Partner

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០

# ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | ៣១ ធ្នូ ២០១៩ | | ៣១ ធ្នូ ២០១៨ | | ០១ មករា ២០១៨ | |
|---|---|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៥ | ២០.៥៩៤ | ៨៣.៩២១ | ២.៥២០ | ១០.១២៥ | ២.៥៨៨ | ១០.៤៤៨ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារជាតិ នៃ កម្ពុជា | ៦ | ២៥.៣១៣.៦៤២ | ១០៣.១៥៣.០៩១ | ១១៣.៨៧២ | ៤៥៧.៥៣៨ | ៣០.០៨៤ | ១២១.៤៤៩ |
| ប្រាក់បញ្ញើ និងការដាក់ប្រាក់នៅធនាគារផ្សេងៗ | ៧ | ១០.២០៣.៦០៧ | ៤១.៥៧៩.៦៩៩ | ៨.០៥៩.១៣៤ | ៣២.៣៨១.៦០១ | ៣.៥០០.៣៦៨ | ១៤.១៣០.៩៨៦ |
| ទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្របក្នុងលទ្ធផលលម្អិតផ្សេងៗ | ៨ | ១២.៥០០ | ៥០.៩៣៨ | ១២.៥០០ | ៥០.២២៥ | ១២.៥០០ | ៥០.៤៦៣ |
| ឥណទាន និងបុរេប្រទានតាមថ្លៃដើមដករំលស់ | ៩ | ៧៩.៥៨៤.៧៩៥ | ៣២៤.៣០៨.០៤០ | ២៦.៧១០.៨៣៣ | ១០៧.៣២៤.១២៧ | ៤.០០៦.៣២៤ | ១៦.១៧៣.៥៣០ |
| ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗតាមថ្លៃដើមដករំលស់ | ១០ | ២.៦៦០.១៣១ | ១០.៨៤០.០៣៤ | - | - | - | - |
| ប្រាក់តម្កល់តាមច្បាប់នៅធនាគារជាតិ នៃ កម្ពុជា | ១១ | ៩៣៧.៥០០ | ៣.៨២០.៣១៣ | ៩៣៧.៥០០ | ៣.៧៦៦.៨៧៥ | ៤០៥.០០០ | ១.៦៣៤.៩៨៥ |
| ទ្រព្យសម្បត្តិ និងបរិក្ខារ | ១២ | ១.៦១១.៣៤១ | ៦.៥៦៦.២១៥ | ៩០៦.១៩៦ | ៣.៦៤១.០៩៦ | ២៩.២៨៦ | ១១៨.២២៨ |
| ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ | ១៣ | ១.៤៨៤.៦៨១ | ៦.០៥០.០៧៥ | ១.០១៨.៧៣៥ | ៤.០៩៣.២៧៧ | - | - |
| ទ្រព្យសកម្មអរូបី | ១៤ | ១០.៣៣៨ | ៤២.១២៧ | ១៥.៨៩២ | ៦៣.៨៥៤ | ១៤.៧៨៦ | ៥៩.៦៩១ |
| ពន្ធពន្យារទ្រព្យសកម្ម | ២៧ | ២៩៣.២៩៣ | ១.១៩៥.១៦៩ | ៨៧.៩៦២ | ៣៥៣.៤៣១ | ១៤.៧២៧ | ៥៩.៤៥៣ |
| ទ្រព្យសកម្មរយៈពេលវែងដែលបានកាន់កាប់សម្រាប់លក់ចេញ | ១៥ | ៦៣៦.២៥៣ | ២.៥៩២.៧៣១ | ៦៣៦.២៥៣ | ២.៥៥៦.៤៦៥ | ១.៣៩២.៤០០ | ៥.៦២១.១១៩ |
| ទ្រព្យសកម្មផ្សេងៗ | ១៦ | ១.២១៧.៣៤៨ | ៤.៩៦០.៦៩១ | ៣០៤.៧៥៣ | ១.២២៤.៤៩៧ | ២៤.៥០៧ | ៩៨.៩៣៣ |
| **ទ្រព្យសកម្មសរុប** | | ១២៣.៩៨៦.០២៣ | ៥០៥.២៤៣.០៤៤ | ៣៨.៨០៦.១៥០ | ១៥៥.៩២៣.១១១ | ៩.៤៣២.៥៧០ | ៣៨.០៧៩.២៨៥ |
| **បំណុល និងមូលធន** | | | | | | | |
| **បំណុល** | | | | | | | |
| ប្រាក់កម្ចី | ១៧ | ៧៧.១២៣.៩០១ | ៣១៤.២៧៩.៨៩៧ | ១៨.០៣៤.៨៣៧ | ៧២.៤៦៣.៩៧៥ | - | - |
| បំណុលភតិសន្យា | ១៣ | ១.២២២.៧១៨ | ៤.៩៨២.៥៧៦ | ៨៥៧.៥១១ | ៣.៤៤៥.៤៧៩ | - | - |
| បំណុលពន្ធក្នុងឆ្នាំ | | ២៦០.៦៨១ | ១.០៦២.២៧៥ | - | - | - | - |
| សំវិធានធនសម្រាប់ការជួសជុលឡើងវិញ | | ១៤៤.២៧៥ | ៥៨៧.៩២១ | ៦៥.២៥៣ | ២៦២.១៨៧ | - | - |
| បំណុលផ្សេងៗ | ១៨ | ៦៩១.៨១៧ | ២.៨១៩.១៥៤ | ៥៧៣.៩០៨ | ២.៣០៥.៩៦២ | ២០៣.១០០ | ៨១៩.៩១៥ |
| **បំណុលសរុប** | | ៧៩.៤៤៣.៣៩២ | ៣២៣.៧៣១.៨២៣ | ១៩.៥៣១.៥០៩ | ៧៨.៤៧៧.៦០៣ | ២០៣.១០០ | ៨១៩.៩១៥ |
| **មូលធន** | | | | | | | |
| ដើមទុន | ១៩ | ៤៣.៧៥០.០០០ | ១៧៨.២៨១.២៥០ | ១៨.៧៥០.០០០ | ៧៥.៣៣៧.៥០០ | ៨.១០០.០០០ | ៣២.៦៩៩.៧០០ |
| ទុនបម្រុងតាមច្បាប់ | | - | - | - | - | ១.៦១៧ | ៦.៥២៨ |
| ទុនបម្រុងផ្សេងៗ | | - | ៣០.៩៣៨ | - | (៥.១២៨) | - | - |
| ចំណេញរក្សាទុក | | ៧៩២.៦៣១ | ៣.១៩៩.០៣៣ | ៥២៤.៦៤១ | ២.១១៣.១៣៦ | ១.១២៧.៨៥៣ | ៤.៥៥៣.១៤២ |
| **មូលធនសរុប** | | ៤៤.៥៤២.៦៣១ | ១៨១.៥១១.២២១ | ១៩.២៧៤.៦៤១ | ៧៧.៤៤៥.៥០៨ | ៩.២២៩.៤៧០ | ៣៧.២៥៩.៣៧០ |
| **បំណុល និងមូលធនសរុប** | | ១២៣.៩៨៦.០២៣ | ៥០៥.២៤៣.០៤៤ | ៣៨.៨០៦.១៥០ | ១៥៥.៩២៣.១១១ | ៩.៤៣២.៥៧០ | ៣៨.០៧៩.២៨៥ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី ១៣ ដល់ទំព័រទី ១០៩ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក

## របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | សម្រាប់ដំណាច់ឆ្នាំ ៣១ ធ្នូ ២០១៩ | | សម្រាប់ដំណាច់ឆ្នាំ ៣១ ធ្នូ ២០១៨ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូលការប្រាក់ | ២០ | ៦.៩៤២.០៨៧ | ២៨.១២៩.៣៣៧ | ១.៤៥៧.១៦៦ | ៥.៨៩៤.២៣៦ |
| ចំណាយការប្រាក់ | ២០ | (២.០៧០.៧៧០) | (៨.៣៩០.៧៦០) | (៩១.៩១០) | (៣៧១.៧៧៦) |
| **ចំណូលការប្រាក់សុទ្ធ** | | ៤.៨៧១.៣១៧ | ១៩.៧៣៨.៥៧៧ | ១.៣៦៥.២៥៦ | ៥.៥២២.៤៦០ |
| ចំណូលកម្រៃជើងសា | ២១ | ២២១.៩៩១ | ៨៩៩.៥០៨ | ៣.១៦៩ | ១២.៨១៩ |
| ចំណាយកម្រៃជើងសា | ២១ | (៤៤៦.៩៣៦) | (១.៨១០.៩៨៥) | (១៣.០៦២) | (៥២.៨៣៦) |
| **ចំណូលកម្រៃជើងសាសុទ្ធ** | | (២២៤.៩៤៥) | (៩១១.៤៧៧) | (៩.៨៩៣) | (៤០.០១៧) |
| ខាតបណ្ដាលមកពីការថយចុះតម្លៃឥណទាន | ២២ | (៧០៧.៣៣៨) | (២.៨៦៦.១៣៤) | (៣០៣.៣១៣) | (១.២២៦.៩០១) |
| ខាតសុទ្ធពីការឈប់កត់ត្រាទ្រព្យសកម្មហិរញ្ញវត្ថុ វាស់វែងតាមថ្លៃដើមដករំលស់ | | (៧៩.៦៤១) | (៣២២.៧០៥) | - | - |
| (ខាត)/ចំណេញផ្សេងៗ - សុទ្ធ | | (៣៥.១៧៥) | (១៤២.៥២៩) | ១៦១ | ៦៥១ |
| ចំណូលប្រតិបត្តិការផ្សេងៗ | ២៣ | ១៧.៨១៤ | ៧២.១៨៣ | ៦៥.០៥៣ | ២៦៣.១៣៩ |
| **ខាតប្រតិបត្តិការផ្សេងៗសរុប - សុទ្ធ** | | (៨០៤.៣៤០) | (៣.២៥៩.១៨៥) | (២៣៨.០៩៩) | (៩៦៣.១១១) |
| ចំណាយបុគ្គលិក | ២៤ | (២.៣២៨.៤៤១) | (៩.៤៣៤.៨៤៣) | (១.00៨.៧០១) | (៤.០៨០.១៩៦) |
| ចំណាយរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី | ២៥ | (៥២១.០១៧) | (២.១១១.១៦១) | (២៣២.១៤៧) | (៩៣៩.០៣៤) |
| ចំណាយប្រតិបត្តិការផ្សេងៗ | ២៦ | (៥៩១.៤២១) | (២.៣៩៦.៤៣៨) | (៥៥៤.៤៨០) | (២.២៤២.៨៧២) |
| **ចំណេញ/(ខាត) មុនពន្ធលើប្រាក់ចំណូល** | | ៤០១.១៥៣ | ១.៦២៥.៤៧៣ | (៦៧៨.០៦៤) | (២.៧៤២.៧៧០) |
| (ចំណាយ)/អត្ថប្រយោជន៍ ពន្ធលើប្រាក់ចំណូល | ២៧ | (១៣៣.១៦៣) | (៥៣៩.៥៧៦) | ៧៣.២៣៥ | ២៩៦.២៣៦ |
| **ចំណេញ/(ខាត) ក្នុងឆ្នាំ** | | ២៦៧.៩៩០ | ១.០៨៥.៨៩៧ | (៦០៤.៨២៩) | (២.៤៤៦.៥៣៤) |
| **លទ្ធផលលម្អិតផ្សេងៗ៖** | | | | | |
| ខ្ទង់ដែលមិនត្រូវបានចាត់ថ្នាក់ឡើងវិញក្នុងចំណេញ-ខាត | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ៣៦.០៦៦ | - | (៥.១២៨) |
| **លទ្ធផលលម្អិតផ្សេងៗក្នុងឆ្នាំ** | | - | ៣៦.០៦៦ | - | (៥.១២៨) |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | ២៦៧.៩៩០ | ១.១២១.៩៦៣ | (៦០៤.៨២៩) | (២.៤៥១.៦៦២) |
| **ចំណេញរបស់៖** | | | | | |
| ភាគទុនិកធនាគារ | | ២៦៧.៩៩០ | ១.០៨៥.៨៩៧ | (៦០៤.៨២៩) | (២.៤៤៦.៥៣៤) |
| **លទ្ធផលលម្អិតសរុបរបស់៖** | | | | | |
| ភាគទុនិកធនាគារ | | ២៦៧.៩៩០ | ១.១២១.៩៦៣ | (៦០៤.៨២៩) | (២.៤៥១.៦៦២) |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី ១៣ ដល់ទំព័រទី ១០៩ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក

## របាយការណ៍បម្រែបម្រួលមូលធន
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | | ដែលជារបស់ភាគទុនិក | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| | កំណត់ | ដើមទុន | | ទុនបម្រុងតាមច្បាប់ | | ចំណេញរក្សាទុក | | ទុនបម្រុងផ្សេងៗ | | សរុប | |
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ដែលបានរាយការណ៍ក្នុងគ្រាមុន** | | ៨.១០០.០០០ | ៣២.៦៩៩.៧០០ | ១.៦១៧ | ៦.៥២៨ | ១.១២៤.៧៦៥ | ៤.៥៤០.៦៧៦ | - | - | ៩.២២៦.៣៨២ | ៣៧.២៤៦.៩០៤ |
| ផលប៉ះពាល់ពីការអនុវត្តគោលការណ៍គណនេយ្យថ្មី ចំពោះការអនុវត្តលើកដំបូង (កំណត់សម្គាល់ ៤) | | - | - | - | - | ៣.០៨៨ | ១២.៤៦៦ | - | - | ៣.០៨៨ | ១២.៤៦៦ |
| **សមតុល្យនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨** | | ៨.១០០.០០០ | ៣២.៦៩៩.៧០០ | ១.៦១៧ | ៦.៥២៨ | ១.១២៧.៨៥៣ | ៤.៥៥៣.១៤២ | - | - | ៩.២២៩.៤៧០ | ៣៧.២៥៩.៣៧០ |
| ខាតក្នុងឆ្នាំ | | - | - | - | - | (៦០៤.៨២៩) | (២.៤៤៦.៥៣៤) | - | - | (៦០៤.៨២៩) | (២.៤៤៦.៥៣៤) |
| លទ្ធផលលម្អិតផ្សេងៗ – លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | - | (៥.១២៨) | - | (៥.១២៨) |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | - | - | - | - | (៦០៤.៨២៩) | (២.៤៤៦.៥៣៤) | - | (៥.១២៨) | (៦០៤.៨២៩) | (២.៤៥១.៦៦២) |
| **ប្រតិបត្តិការជាមួយភាគទុនិកធនាគារ ក្នុងនាមជាភាគទុនិកធនាគារ ៖** | | | | | | | | | | | |
| ការចេញផ្សាយដើមទុន | | ១០.៦៥០.០០០ | ៤៣.០៧៩.២៥០ | - | - | - | - | | | ១០.៦៥០.០០០ | ៤៣.០៧៩.២៥០ |
| ការផ្ទេរទៅប្រាក់ចំណេញរក្សាទុក | | - | - | (១.៦១៧) | (៦.៥២៨) | ១.៦១៧ | ៦.៥២៨ | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៤៤១.៤៥០) | - | - | - | - | - | - | - | (៤៤១.៤៥០) |
| **ប្រតិបត្តិការសរុបជាមួយភាគទុនិកធនាគារ** | | ១០.៦៥០.០០០ | ៤២.៦៣៧.៨០០ | (១.៦១៧) | (៦.៥២៨) | ១.៦១៧ | ៦.៥២៨ | - | - | ១០.៦៥០.០០០ | ៤២.៦៣៧.៨០០ |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨** | | ១៨.៧៥០.០០០ | ៧៥.៣៣៧.៥០០ | - | - | ៥២៤.៦៤១ | ២.១១៣.១៣៦ | - | (៥.១២៨) | ១៩.២៧៤.៦៤១ | ៧៧.៤៤៥.៥០៨ |
| **សមតុល្យដែលបានរាយការណ៍ឡើងវិញនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩** | | ១៨.៧៥០.០០០ | ៧៥.៣៣៧.៥០០ | - | - | ៥២៤.៦៤១ | ២.១១៣.១៣៦ | - | (៥.១២៨) | ១៩.២៧៤.៦៤១ | ៧៧.៤៤៥.៥០៨ |
| ចំណេញក្នុងឆ្នាំ | | - | - | - | - | ២៦៧.៩៩០ | ១.០៨៥.៨៩៧ | - | - | ២៦៧.៩៩០ | ១.០៨៥.៨៩៧ |
| លទ្ធផលលម្អិតផ្សេងៗ – លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | - | - | - | - | - | - | ៣៦.០៦៦ | - | ៣៦.០៦៦ |
| **លទ្ធផលលម្អិតសរុបក្នុងឆ្នាំ** | | - | - | - | - | ២៦៧.៩៩០ | ១.០៨៥.៨៩៧ | - | ៣៦.០៦៦ | ២៦៧.៩៩០ | ១.១២១.៩៦៣ |
| **ប្រតិបត្តិការជាមួយភាគទុនិកធនាគារ ក្នុងនាមជាភាគទុនិកធនាគារ ៖** | | | | | | | | | | | |
| ការចេញផ្សាយដើមទុន | ១៩ | ២៥.០០០.០០០ | ១០១.៣០០.០០០ | - | - | - | - | | | ២៥.០០០.០០០ | ១០១.៣០០.០០០ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ១.៦៤៣.៧៥០ | - | - | - | - | | | - | ១.៦៤៣.៧៥០ |
| **ប្រតិបត្តិការសរុបជាមួយភាគទុនិកធនាគារ** | | ២៥.០០០.០០០ | ១០២.៩៤៣.៧៥០ | - | - | - | - | | | ២៥.០០០.០០០ | ១០២.៩៤៣.៧៥០ |
| **សមតុល្យនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩** | | ៤៣.៧៥០.០០០ | ១៧៨.២៨១.២៥០ | - | - | ៧៩២.៦៣១ | ៣.១៩៩.០៣៣ | - | ៣០.៩៣៨ | ៤៤.៥៤២.៦៣១ | ១៨១.៥១១.២២១ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី ១៣ ដល់ទំព័រទី ១០៩ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

# ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក

## របាយការណ៍លំហូរសាច់ប្រាក់
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

| | កំណត់សម្គាល់ | ២០១៩ | | ២០១៨ | |
|---|---|---|---|---|---|
| | | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| សាច់ប្រាក់បានប្រើក្នុងប្រតិបត្តិការ | ២៨ | (៥៧.១៣២.១២២) | (២៣១.៤៩៩.៣៥៦) | (២៤.០២០.៦២៧) | (៩៧.១៦៣.៤៣៨) |
| ការប្រាក់បានទទួល | | ៦.៥៩៧.៤៨៨ | ២៦.៧៣៣.០២១ | ១.៣៣៤.៤៣១ | ៥.៣៩៧.៧៧៣ |
| ការប្រាក់បានបង់ | | (២.០០២.១៣០) | (៨.១១២.៦៣១) | (៧៤.៣៧០) | (៣០០.៨២៧) |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (៧៧.៨១៣) | (៣១៥.២៩៨) | - | - |
| **សាច់ប្រាក់បានប្រើក្នុងសកម្មភាពប្រតិបត្តិការ** | | (៥២.៦១៤.៥៧៧) | (២១៣.១៩៤.២៦៤) | (២២.៧៦០.៥៦៦) | (៩២.០៦៦.៤៩២) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញទ្រព្យសម្បត្តិ និងបរិក្ខារ | ១២ | (៩៨១.៩៧៦) | (៣.៩៧៨.៩៦៧) | (១.០១៥.១១៧) | (៤.១០៦.១៤៨) |
| ការទិញទ្រព្យសកម្មអរូបី | ១៤ | (៥៧៤) | (២.៣២៦) | (៥.៦០០) | (២២.៦៥២) |
| ទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ វាស់វែងតាមថ្លៃដើមដករំលស់ | | (២.៦៩៤.២៦៧) | (១០.៩១៧.១៧០) | - | - |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ | | - | - | ១.១២០ | ៤.៥៣០ |
| **សាច់ប្រាក់បានប្រើក្នុងសកម្មភាពវិនិយោគ** | | (៣.៦៤២.២៣៨) | (១៤.៧៥៨.៣៤៩) | (១.០១៩.៥៩៧) | (៤.១២៤.២៧០) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពហិរញ្ញប្បទាន** | | | | | |
| សាច់ប្រាក់បានពីការចេញផ្សាយភាគហ៊ុន | ១៩ | ២៥.០០០.០០០ | ១០១.៣០០.០០០ | ១០.៦៥០.០០០ | ៤៣.០៧៩.២៥០ |
| សាច់ប្រាក់បានពីប្រាក់កម្ចី | ១៧ | ៦២.៧២៧.១២០ | ២៥៤.១៧០.២៩០ | ១៨.០០០.០០០ | ៧២.៨១០.០០០ |
| ការសងប្រាក់កម្ចី | ១៧ | (៣.៧៤១.១៧៤) | (១៥.១៥៩.២៣៧) | - | - |
| ធាតុប្រាក់ដើមនៃការទូទាត់ភតិសន្យា | | (៣៤៧.៨៣៧) | (១.៤០៩.៤៣៦) | (១៩៦.៣៥៥) | (៧៩៤.២៥៦) |
| **សាច់ប្រាក់បានពីសកម្មភាពហិរញ្ញប្បទាន** | | ៨៣.៦៣៨.១០៩ | ៣៣៨.៩០១.៦១៧ | ២៨.៤៥៣.៦៤៥ | ១១៥.០៩៤.៩៩៤ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | ២៧.៣៤៦.៧១៥ | ១១០.៨០៨.៨៩០ | ៤.៦៧៣.៤៨២ | ១៨.៩០៤.២៣២ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូលដើមឆ្នាំ | | ៨.១៩៤.៣៧២ | ៣២.៩២៤.៩៨៦ | ៣.៥២០.៨៩០ | ១៤.២១៣.៨៣៣ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | ១.០៩៦.០៥៤ | - | (១៩៣.០៧៩) |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូលដំណាច់ឆ្នាំ** | ២៩ | ៣៥.៥៤១.០៨៧ | ១៤៤.៨២៩.៩៣០ | ៨.១៩៤.៣៧២ | ៣២.៩២៤.៩៨៦ |

កំណត់សម្គាល់ដែលភ្ជាប់មកជាមួយពីទំព័រទី ១៣ ដល់ទំព័រទី ១០៩ ជាផ្នែកនៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

## ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ១. ព័ត៌មានទូទៅ

ធនាគារបានចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០០៨ ក្រោមវិញ្ញាបនបត្រចុះបញ្ជីលេខ Co.០០០២០២១៨ ចេញដោយក្រសួងពាណិជ្ជកម្ម។ ធនាគារបានទទួលអាជ្ញាប័ណ្ណអចិន្ត្រៃយ៍ជាធនាគារឯកទេស ពីធនាគារជាតិ នៃ កម្ពុជា (ហៅកាត់ថា “ធនាគារកណ្តាល”) នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៨ ដើម្បីធ្វើប្រតិបត្តិការជាធនាគារឯកទេស។

ធនាគារបានប្តូរនាមករណ៍របស់ខ្លួនពី “ធនាគារ ឯកទេស តូម៉ាតូ” ទៅជា “ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក” នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨ ដោយទទួលបានការអនុម័តពីធនាគារកណ្តាល។ ធនាគារបានទទួលបានអាជ្ញាប័ណ្ណថ្មីអំពីនាមករណ៍ថ្មីរបស់ខ្លួន ដែលត្រូវបានអនុម័តដោយធនាគារកណ្តាលនៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៨។

សកម្មភាពអាជីវកម្មចម្បងរបស់ធនាគារគឺការផ្តល់ឥណទានទិញយានយន្ត និងឥណទានទូទៅ ដល់សហគ្រាសធុនតូច និងមធ្យម ដែលកំពុងធ្វើប្រតិបត្តិការអាជីវកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

ការិយាល័យចុះបញ្ជីរបស់ធនាគារមានទីតាំងស្ថិតនៅជាន់ទី២១ និង ២២ នៃអគារលេខមួយ ផ្លូវលេខ ៣៦០ សង្កាត់ បឹងកេងកង ១ ខណ្ឌ ចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ធនាគារមានបុគ្គលិកចំនួន ១៤១ នាក់ (២០១៨ ៖ ៨៩ នាក់)។

ក្រុមប្រឹក្សាភិបាលបានអនុម័តឱ្យចេញផ្សាយរបាយការណ៍ហិរញ្ញវត្ថុ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០២០។

### ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ

គោលការណ៍គណនេយ្យសំខាន់ៗដែលបានប្រើប្រាស់ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ត្រូវបានបង្ហាញខាងក្រោម។ គោលការណ៍ទាំងនេះ ត្រូវបានអនុវត្តយ៉ាងមានសង្គតិភាពគ្រប់ឆ្នាំដែលបានដាក់បង្ហាញទាំងអស់ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

នៅថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៩ ក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រកាសដាក់ឱ្យប្រើ ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃ កម្ពុជា (ហៅកាត់ថា “CIFRS”) ដែលផ្អែកទាំងស្រុង ទៅតាមស្តង់ដារទាំងអស់ ដែលចេញផ្សាយដោយក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ (ហៅកាត់ថា “IASB”) រួមទាំងបំណកស្រាយ និង វិសោធនកម្មពាក់ព័ន្ធផ្សេងៗ ចំពោះស្តង់ដារនីមួយៗដែលអាចកើតមានឡើងក្នុងកាលៈទេសៈជាក់លាក់ណាមួយ ដោយការបន្ថែមពាក្យ “កម្ពុជា”។ អង្គភាពដែលមានការទទួលខុសត្រូវជាសាធារណៈ ត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនឱ្យស្របទៅតាម CIFRS សម្រាប់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១២ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ។ សារាចរណែនាំលេខ ០៨៦ សហវ.កជគ ចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០១២ ដែលចេញដោយក្រុមប្រឹក្សាជាតិគណនេយ្យ បានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុពន្យារពេលការអនុវត្ត CIFRS រហូតដល់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៦ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ។

**ធនាគារ ឯកទេស ខេមី ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១ មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (ត)

យោងទៅតាមសារាចរណែនាំលេខ ០៥៨ សហវ.កជគ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៦ ដែលចេញដោយក្រុមប្រឹក្សាជាតិគណនេយ្យ នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអនុញ្ញាតឱ្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ពន្យារពេលអនុវត្ត CIFRS រហូតដល់ការិយបរិច្ឆេទគណនេយ្យដែលចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៩ ឬការិយបរិច្ឆេទគណនេយ្យបន្ទាប់ពីនេះ។

របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយអនុលោមទៅតាម ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិ នៃ កម្ពុជា (CIFRS) ដែលផ្អែកទាំងស្រុងទៅតាមស្តង់ដារទាំងអស់ដែលបានចេញផ្សាយដោយ ក្រុមប្រឹក្សាស្តង់ដារគណនេយ្យអន្តរជាតិ រួមទាំងបំណកស្រាយ និងវិសោធនកម្មផ្សេងៗ ដែលអាចកើតមានក្នុងកាលៈទេសៈណាមួយចំពោះស្តង់ដារនីមួយៗ។

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារត្រូវបានរៀបចំតាមវិធីសាស្ត្រថ្លៃដើម លើកលែងតែឧបករណ៍មូលធន ដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលស្របទៅតាម CIFRS តម្រូវឱ្យប្រើប្រាស់ការប៉ាន់ស្មានគណនេយ្យជាក់លាក់សំខាន់ៗ។ ហើយវាក៏តម្រូវឱ្យគណៈគ្រប់គ្រងធ្វើការវិនិច្ឆ័យរបស់ខ្លួន នៅក្នុងដំណើរការនៃការអនុវត្តគោលការណ៍គណនេយ្យនេះផងដែរ។ ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានលាតត្រដាងនៅក្នុងកំណត់សម្គាល់ ៣ ។

របាយការណ៍ហិរញ្ញវត្ថុសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ គឺជារបាយការណ៍ហិរញ្ញវត្ថុលើកដំបូងដែលត្រូវបានរៀបចំដោយអនុលោមទៅតាម CIFRS។ ក្នុងការអនុវត្ត CIFRS លើកដំបូង ធនាគារបានរៀបចំការពន្យល់ពីការផ្លាស់ប្តូរពីគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និង ស្តង់ដារគណនេយ្យកម្ពុជា (“CAS”) មកអនុវត្ត CIFRS នៅក្នុងកំណត់សម្គាល់ ៤ ។

### ២.២ ស្តង់ដារគណនេយ្យថ្មី វិសោធនកម្ម និងបំណកស្រាយដែលធនាគារមិនទាន់បានអនុវត្ត

ធនាគារមិនបានអនុវត្តមុនកាលកំណត់នូវស្តង់ដារគណនេយ្យថ្មី និងបំណកស្រាយដែលត្រូវបានចេញផ្សាយរួច ប៉ុន្តែមិនទាន់ចាំបាច់ត្រូវអនុវត្តសម្រាប់ការិយបរិច្ឆេទរាយការណ៍ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ទេ។ ធនាគារមិនរំពឹងថាស្តង់ដារទាំងនេះមានផលប៉ះពាល់ជាសារវន្តលើមូលធនរបស់ធនាគារ សម្រាប់ការិយបរិច្ឆេទរាយការណ៍នេះ និងការិយបរិច្ឆេទរាយការណ៍នាពេលអនាគត និងចំពោះប្រតិបត្តិការនាពេលអនាគតខាងមុខនេះទេ។

### ២.៣ រូបិយប័ណ្ណបរទេស

(ក) រូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញ

គណនីទាំងអស់ដែលមាននៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារ ត្រូវបានវាស់តម្លៃដោយប្រើប្រាស់រូបិយប័ណ្ណនៃបរិយាកាសសេដ្ឋកិច្ចចម្បងដែលធនាគារធ្វើប្រតិបត្តិការ (ហៅកាត់ថា “រូបិយប័ណ្ណគោល”)។ ធនាគាររក្សាបញ្ជីគណនេយ្យ និង របាយការណ៍ហិរញ្ញវត្ថុ ជាប្រាក់ដុល្លារអាមេរិក ដែលជារូបិយប័ណ្ណគោលរបស់ធនាគារ។ ការកំណត់យកប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណគោល ដោយសារវាមានឥទ្ធិពលជាសារវន្តលើប្រតិបត្តិការរបស់ធនាគារ។ របាយការណ៍ហិរញ្ញវត្ថុនេះត្រូវបានបង្ហាញជាប្រាក់ដុល្លារអាមេរិកដែលជារូបិយប័ណ្ណគោល និងរូបិយប័ណ្ណសម្រាប់បង្ហាញរបស់ធនាគារ។

**ធនាគារ ឯកទេស ខេមឺ ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៣ រូបិយប័ណ្ណបរទេស (ត)

(ខ) ប្រតិបត្តិការ និងសមតុល្យ

ប្រតិបត្តិការជារូបិយប័ណ្ណបរទេស ត្រូវបានកត់ត្រាប្តូរទៅជារូបិយប័ណ្ណគោល ដោយប្រើអត្រាប្តូរប្រាក់នាកាលបរិច្ឆេទនៃប្រតិបត្តិការនោះ។ ចំណេញនិងខាតពីប្រតិបត្តិការទាំងនេះ និងពីការប្តូរទ្រព្យសកម្ម និងបំណុលរូបិយវត្ថុជារូបិយប័ណ្ណបរទេសផ្សេងៗ ជាទូទៅត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត។

ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណដែលពាក់ព័ន្ធនឹងប្រាក់កម្ចី ត្រូវបានដាក់បង្ហាញនៅក្នុងរបាយការណ៍ចំណេញ-ខាត ក្នុងខ្ទង់ចំណាយការប្រាក់។ ចំណេញ និងខាតពីការប្តូររូបិយប័ណ្ណផ្សេងៗទៀតទាំងអស់ ត្រូវបានដាក់បង្ហាញនៅក្នុងរបាយការណ៍ចំណេញ-ខាត តាមមូលដ្ឋានចំនួនទឹកប្រាក់សុទ្ធ ក្នុងខ្ទង់ "ចំណេញ/(ខាត)ផ្សេងៗ - សុទ្ធ"។

(គ) ការបង្ហាញជាប្រាក់រៀល

អនុលោមតាមច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម តម្រូវឱ្យមានការកត់ត្រាប្តូរចំនួនទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុពីប្រាក់ដុល្លារអាមេរិក ទៅជាប្រាក់រៀល។ របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ និងលំហូរសាច់ប្រាក់ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាមធ្យមប្រចាំឆ្នាំ។ ទ្រព្យសកម្ម និងបំណុលដែលបានដាក់បង្ហាញក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុនីមួយៗ និងមូលធនរបស់ភាគទុនិក ត្រូវបានប្តូរដោយប្រើអត្រាថ្ងៃបិទបញ្ជីនាកាលបរិច្ឆេទរាយការណ៍។ លម្អៀងពីការប្តូរមូលធនភាគទុនិកត្រូវបានកត់ត្រាផ្ទាល់ក្នុងមូលធន ហើយរាល់លម្អៀងពីការប្តូរផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាក្នុងលទ្ធផលលម្អិតផ្សេងៗ។

ធនាគារបានប្រើអត្រាប្តូរប្រាក់ផ្លូវការដែលផ្សព្វផ្សាយដោយធនាគារកណ្តាល។ គិតត្រឹមកាលបរិច្ឆេទរាយការណ៍ អត្រាមធ្យមសម្រាប់ឆ្នាំនេះ គឺ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៥២ រៀល (២០១៨ ៖ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៤៥ រៀល) ហើយអត្រាបិទបញ្ជីគឺ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៧៥រៀល (២០១៨ ៖ ១ដុល្លារអាមេរិក ស្មើនឹង ៤.០១៨រៀល)។

ចំពោះការដាក់បង្ហាញតាម CIFRS 1 គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ អត្រាមធ្យមគឺ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៤៥ រៀល ហើយអត្រាបិទបញ្ជីគឺ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៣៧រៀល។

### ២.៤ ឧបករណ៍ហិរញ្ញវត្ថុ

### ២.៤.១ ទ្រព្យសកម្មហិរញ្ញវត្ថុ

(ក) ចំណាត់ថ្នាក់

ធនាគារបែងចែកទ្រព្យសកម្មហិរញ្ញវត្ថុ ទៅតាមប្រភេទនៃការវាស់វែងដូចខាងក្រោម៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ រួមមាន សាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើនិងការដាក់ប្រាក់នៅធនាគារកណ្តាល ប្រាក់បញ្ញើនិងការដាក់ប្រាក់នៅធនាគារផ្សេងៗ ឥណទាន និងបុរេប្រទាន និងទ្រព្យសកម្មផ្សេងៗ ឬ
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងនាពេលបន្ទាប់មក តាមតម្លៃសមស្របក្នុង OCI ។

ការធ្វើចំណាត់ថ្នាក់នេះគឺអាស្រ័យទៅតាមគំរូអាជីវកម្មរបស់ធនាគារ ក្នុងការគ្រប់គ្រងទ្រព្យសកម្មហិរញ្ញវត្ថុ និងលក្ខខណ្ឌក្នុងកិច្ចសន្យានៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។

**ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ២.៤ ឧបករណ៍ហិរញ្ញវត្ថុ (ត)

### ២.៤.១ ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

(ក) ចំណាត់ថ្នាក់ (ត)

ចំពោះទ្រព្យសកម្មដែលត្រូវបានវាស់វែងតាមតម្លៃសមស្រប ចំណេញឬខាតនឹងត្រូវបានកត់ត្រានៅក្នុងចំណេញខាត ឬក្នុង OCI ។ ចំពោះការវិនិយោគក្នុងឧបករណ៍មូលធនដែលត្រូវបានកាន់កាប់សម្រាប់ការជួញដូរ ការកត់ត្រាគឺអាស្រ័យទៅលើជម្រើសរបស់ធនាគារនាពេលកត់ត្រាលើកដំបូង ថាតើធនាគារបានកត់ត្រាការវិនិយោគមូលធនតាមតម្លៃសមស្របក្នុងលទ្ធផលលម្អិត (FVOCI) ឬទេ។

(i) ទ្រព្យសកម្មហិរញ្ញវត្ថុវាស់វែងតាមតម្លៃសមស្របក្នុង OCI រួមមាន៖

- មូលបត្រកម្មសិទ្ធិដែលមិនត្រូវបានកាន់កាប់សម្រាប់ការជួញដូរ ហើយដែលធនាគារបានជ្រើសរើសនាពេលកត់ត្រាលើកដំបូង តាមតម្លៃសមស្របក្នុងលទ្ធផលលម្អិតផ្សេងៗ ជាជាងក្នុងចំណេញ-ខាត។

(ii) ធនាគារបានធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ខ្លួនតាមថ្លៃដើមដករំលស់ តែក្នុងករណីដែលស្របតាមលក្ខណៈវិនិច្ឆ័យដូចខាងក្រោមប៉ុណ្ណោះ ៖

- ទ្រព្យសកម្មដែលត្រូវបានកាន់កាប់ក្នុងគំរូអាជីវកម្ម ដែលមានគោលបំណងដើម្បីប្រមូលលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យា និង
- លក្ខខណ្ឌក្នុងកិច្ចសន្យាផ្តល់នូវកំណើនក្នុងកាលបរិច្ឆេទជាក់លាក់នានា ចំពោះលំហូរសាច់ប្រាក់ដែលជាការទូទាត់ប្រាក់ដើម និងការប្រាក់ទាំងស្រុង ទៅលើចំនួនប្រាក់ដើមដែលនៅមិនទាន់ទូទាត់។

(ខ) ការកត់ត្រា និងការឈប់កត់ត្រា

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានកត់ត្រា នៅពេលដែលធនាគារក្លាយជាភាគីមួយក្នុងកិច្ចសន្យានៃឧបករណ៍ណាមួយ។ ការទិញនិងការលក់ទ្រព្យសកម្មហិរញ្ញវត្ថុតាមមធ្យោបាយធម្មតា ត្រូវបានកត់ត្រានាកាលបរិច្ឆេទជួញដូរ ជាកាលបរិច្ឆេទដែលធនាគារធ្វើការទិញ ឬលក់ទ្រព្យសកម្ម។

ទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគេឈប់កត់ត្រា នៅពេលដែលសិទ្ធិក្នុងការទទួលលំហូរសាច់ប្រាក់ពីទ្រព្យសកម្មនោះបានហួសកាលកំណត់ ឬត្រូវបានផ្ទេរ ហើយធនាគារបានផ្ទេរនូវរាល់ហានិភ័យជាសារវន្ត និងផលកម្មសិទ្ធិទាំងអស់។ ចំណេញឬខាតពីការឈប់កត់ត្រាទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ ត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត នៅពេលដែលទ្រព្យសកម្មហិរញ្ញវត្ថុត្រូវបានគេឈប់កត់ត្រា។

**ធនាគារ ឯកទេស ខេមី ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ២.៤ ឧបករណ៍ហិរញ្ញវត្ថុ (ត)

### ២.៤.១ ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

(គ) ការវាស់វែង

នាពេលកត់ត្រាលើកដំបូង ធនាគារវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុតាមតម្លៃសមស្រប បូកបន្ថែមជាមួយនឹងចំណាយប្រតិបត្តិការផ្សេងៗដែលបានចំណាយផ្ទាល់ក្នុងការទិញទ្រព្យសកម្មហិរញ្ញវត្ថុ ក្នុងករណីដែលទ្រព្យសកម្មហិរញ្ញវត្ថុមិនត្រូវបានវាស់វែងតាមតម្លៃសមស្របក្នុងចំណេញ-ខាត(FVPL)។ ចំណាយប្រតិបត្តិការនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានកត់ត្រាតាម FVPL ត្រូវបានកត់ត្រាជាចំណាយក្នុងចំណេញ-ខាត។ បន្ទាប់ពីការកត់ត្រាលើកដំបូងភ្លាម សំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក (ECL) ត្រូវបានកត់ត្រាសម្រាប់ទ្រព្យសកម្មដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ដែលធ្វើឱ្យមានការខាតតាមគណនេយ្យមួយ ដែលត្រូវបានកត់ត្រាក្នុងចំណេញ-ខាត នៅពេលទ្រព្យសកម្មមួយត្រូវបានបង្កើតឡើងថ្មី។

<u>ឧបករណ៍បំណុល</u>

ការវាស់វែងឧបករណ៍បំណុលគឺអាស្រ័យទៅលើគំរូអាជីវកម្មរបស់ធនាគារ ក្នុងការគ្រប់គ្រងទ្រព្យសកម្ម និងលក្ខណៈនៃលំហូរសាច់ប្រាក់របស់ទ្រព្យសកម្មនោះ។ ផ្អែកតាមកត្តាទាំងនេះ ធនាគារធ្វើចំណាត់ថ្នាក់ឧបករណ៍បំណុលរបស់ខ្លួនជាទ្រព្យសកម្មហិរញ្ញវត្ថុដែលបានវាស់វែងតាមថ្លៃដើមដករំលស់។

ថ្លៃដើមដករំលស់៖ ទ្រព្យសកម្មដែលត្រូវបានកាន់កាប់សម្រាប់ការប្រមូលលំហូរសាច់ប្រាក់ក្នុងកិច្ចសន្យា ដែលលំហូរសាច់ប្រាក់នោះគឺជាការទូទាត់ប្រាក់ដើម និងការប្រាក់ទាំងស្រុង (SPPI) និងមិនត្រូវបានចាត់ថ្នាក់ក្នុង FVPL ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់។ តម្លៃយោងនៃទ្រព្យសកម្មទាំងនេះត្រូវបានកែតម្រូវទៅតាមសំវិធានធនការខាតឥណទានរំពឹងទុកដែលបានកត់ត្រា។ ចំណូលការប្រាក់ពីទ្រព្យសកម្មហិរញ្ញវត្ថុទាំងនេះត្រូវបានដាក់បញ្ចូលនៅក្នុង “ចំណូលការប្រាក់” ដោយប្រើវិធីសាស្ត្រអត្រាការប្រាក់មានប្រសិទ្ធភាព។

<u>ឧបករណ៍មូលធន</u>

ធនាគារវាស់វែងឧបករណ៍មូលធនទាំងអស់នៅពេលបន្ទាប់មក តាមតម្លៃសមស្រប។ ប្រសិនបើធនាគារជ្រើសរើសបង្ហាញចំណេញឬខាតនៃតម្លៃសមស្របចំពោះការវិនិយោគមូលធន ក្នុង OCI នោះមិនមានការចាត់ថ្នាក់ឡើងវិញនាពេលបន្ទាប់មក ចំពោះចំណេញឬខាតនៃតម្លៃសមស្របទៅក្នុងចំណេញ-ខាតទេ ដោយមានការអនុញ្ញាតឱ្យឈប់កត់ត្រាការវិនិយោគនោះ។ ធនាគារបានជ្រើសរើសធ្វើចំណាត់ថ្នាក់ការវិនិយោគមូលធនមិនមែនការជួញដូរទាំងអស់ តាមតម្លៃសមស្រប ក្នុងលទ្ធផលលម្អិតផ្សេងៗ (FVOCI)។ បម្រែបម្រួលណាមួយនៃតម្លៃសមស្របរបស់ការវិនិយោគនេះ នឹងត្រូវបានកត់ត្រានៅក្នុង OCI ហើយនឹងមិនត្រូវបានចាត់ថ្នាក់ឡើងវិញនៅពេលបន្ទាប់មកក្នុងចំណេញ-ខាត នៅពេលដែលវាត្រូវលក់ចេញទេ។ ភាគលាភបានពីការវិនិយោគប្រភេទនេះ ត្រូវបានបន្តកត់ត្រាក្នុងចំណេញ-ខាត ជាចំណូលផ្សេងៗ នៅ ពេលដែលធនាគារមានសិទ្ធិទទួលការទូទាត់នោះ។ ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ (និងការកត់ត្រាការខាត ដែលបណ្តាលមកពីការថយចុះតម្លៃត្រឡប់ទៅវិញ) ចំពោះការវិនិយោគមូលធន ដែលត្រូវបានវាស់វែងតាម FVOCI មិនត្រូវបានរាយការណ៍ដាច់ដោយឡែកពីការប្រែប្រួលតម្លៃសមស្របទេ។

**ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៤ ឧបករណ៍ហិរញ្ញវត្ថុ (ត)

### ២.៤.១ ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)

(ឃ) ការធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ

ធនាគារធ្វើចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុឡើងវិញ នៅពេលដែលគំរូអាជីវកម្មសម្រាប់ការគ្រប់គ្រងទ្រព្យសកម្មរបស់ខ្លួន មានការប្រែប្រួល។

(ង) ការថយចុះតម្លៃ

ធនាគារវាយតម្លៃការខាតឥណទានរំពឹងទុក (“ECL”) តាមមូលដ្ឋានរំពឹងមើលទៅថ្ងៃអនាគត ដែលទាក់ទងជាមួយនឹងឧបករណ៍បំណុលរបស់ខ្លួនដែលវាស់វែងតាមថ្លៃដើមដករំលស់ និងតាម FVOCI ព្រមទាំងហានិភ័យដែលកើតពីកិច្ចសន្យាផ្តល់ឥណទាន (រួមទាំង ឥណទានវិបារូបន៍ និងហ្វាស៊ីលីធីដែលអាចប្រើប្រាស់ឡើងវិញ) និងកិច្ចសន្យាធានាផ្នែកហិរញ្ញវត្ថុ។ ធនាគារកត់ត្រាសំវិធានធនសម្រាប់ការខាតបង់ចំពោះការខាតប្រភេទនេះ នាកាលបរិច្ឆេទរាយការណ៍។ ការវាស់វែង ECL ឆ្លុះបញ្ចាំងពី ៖

- ចំនួនលម្អៀង និងចំនួនដែលបានថ្លឹងប្រូបាប ដែលត្រូវបានកំណត់ដោយធ្វើការវាយតម្លៃលើលទ្ធភាពដែលអាចកើតឡើងមួយចំនួន
- ពេលវេលានៃតម្លៃទឹកប្រាក់ និង
- ព័ត៌មានដែលមានភាពសមហេតុផល និងមានការគាំទ្រ ដែលអាចរកបានដោយពុំចាំបាច់មានការចំណាយ និងការខំប្រឹងប្រែងលើសលប់ នាកាលបរិច្ឆេទរាយការណ៍ អំពីព្រឹត្តិការណ៍នាពេលបច្ចុប្បន្ន និងការព្យាករអំពីលក្ខខណ្ឌនាពេលអនាគត

ធនាគារបានអនុវត្តវិធីសាស្ត្របីដំណាក់កាល ចំពោះការវាស់វែងការខាតឥណទានរំពឹងទុក (ECLs) សម្រាប់ប្រភេទដូចខាងក្រោម៖

- ឧបករណ៍បំណុលដែលវាស់វែងតាមថ្លៃដើមដករំលស់ និង
- កិច្ចសន្យាផ្តល់ឥណទាន (រួមទាំង ឥណទាន និងបុរេប្រទានដែលមិនទាន់បានដកប្រាក់)

អនុវត្តវិធីសាស្ត្របីដំណាក់កាលផ្អែកទៅលើបម្រែបម្រួលហានិភ័យឥណទាន ចាប់តាំងពីការកត់ត្រាលើកដំបូង៖

ដំណាក់កាលទី ១ ៖ ECL ១២ខែ

ហានិភ័យទាំងឡាយណា ដែលមិនមានកំណើនហានិភ័យឥណទានគួរឱ្យកត់សម្គាល់ចាប់តាំងពីការកត់ត្រាលើកដំបូង និងដែលមិនមានការថយចុះតម្លៃឥណទាននៅពេលចាប់ផ្តើមដំបូង ជាផ្នែកនៃ ECL ពេញមួយអាយុកាល ដែលពាក់ព័ន្ធនឹងប្រូបាបនៃការមិនសងប្រាក់ ដែលកើតឡើងក្នុងរយៈពេល១២ខែបន្ទាប់ ត្រូវបានកត់ត្រាក្នុង ECL ១២ខែ។

**ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

**២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)**

**២.៤ ឧបករណ៍ហិរញ្ញវត្ថុ (ត)**

**២.៤.១ ទ្រព្យសកម្មហិរញ្ញវត្ថុ (ត)**

(ង) ការថយចុះតម្លៃ (ត)

ដំណាក់កាលទី ២ ៖ ECL ពេញមួយអាយុកាល – មិនមានការថយចុះតម្លៃឥណទាន

ហានិភ័យទាំងឡាយណា ដែលមានកំណើនហានិភ័យឥណទានជាសារវន្ត ចាប់តាំងពីការកត់ត្រាលើកដំបូង ប៉ុន្តែមិនមានភ័ស្តុតាងជាក់ស្តែងបង្ហាញពីការថយចុះតម្លៃ ត្រូវបានកត់ត្រាក្នុង ECL ពេញមួយអាយុកាល (ឧ. ឆ្លុះបញ្ចាំងពីតម្លៃនៅសល់ពេញមួយអាយុកាលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ)។

ដំណាក់កាលទី ៣ ៖ ECL ពេញមួយអាយុកាល – មានការថយចុះតម្លៃឥណទាន

ហានិភ័យត្រូវបានវាយតម្លៃថាមានការថយចុះតម្លៃឥណទាន នៅពេលដែលមានព្រឹត្តិការណ៍មួយ ឬច្រើនបានកើតឡើង ហើយមានផលប៉ះពាល់ធ្ងន់ធ្ងរចំពោះលំហូរសាច់ប្រាក់ប៉ាន់ស្មាននាពេលអនាគតរបស់ទ្រព្យសកម្ម។ ចំពោះហានិភ័យដែលមានការថយចុះតម្លៃឥណទាន វាត្រូវបានកត់ត្រាក្នុង ECL ពេញមួយអាយុកាល ហើយចំណូលការប្រាក់ត្រូវបានគណនាតាមអត្រាការប្រាក់មានប្រសិទ្ធភាព ចំពោះថ្លៃដើមដករំលស់ (កាត់កងជាមួយសំវិធានធន) ជាជាងកត់ត្រាតាមចំនួនតម្លៃយោងដុល។

**២.៤.២ បំណុលហិរញ្ញវត្ថុ**

បំណុលហិរញ្ញវត្ថុត្រូវបានកត់ត្រានៅពេលដែលធនាគារក្លាយជាភាគីមួយ នៅក្នុងកិច្ចសន្យានៃឧបករណ៍ណា មួយ។ បំណុលហិរញ្ញវត្ថុរបស់ធនាគាររួមមាន ប្រាក់កម្ចី និងបំណុលហិរញ្ញវត្ថុផ្សេងៗ។

បំណុលហិរញ្ញវត្ថុត្រូវបានកត់ត្រាលើកដំបូងតាមតម្លៃសមស្រប ដកចំណាយប្រតិបត្តិការ ចំពោះបំណុលប្រតិបត្តិការទាំងអស់ ដែលមិនវាស់វែងតាមតម្លៃសមស្រប ក្នុងចំណេញ-ខាត។ បំណុលហិរញ្ញវត្ថុដែលត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ មានដូចជា ប្រាក់កម្ចី និងបំណុលផ្សេងៗ។

បំណុលហិរញ្ញវត្ថុត្រូវបានគេឈប់កត់ត្រា នៅពេលដែលវាត្រូវបានបង្វិលអស់ ឬបើមិនដូច្នោះទេវាត្រូវបានព្រមព្រៀងឱ្យបញ្ឈប់ការសងប្រាក់តទៅទៀត។

**ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ២.៤ ឧបករណ៍ហិរញ្ញវត្ថុ (ត)

### ២.៤.៣ កិច្ចសន្យាផ្តល់ឥណទាន (ឥណទាន និងបុរេប្រទានដែលមិនទាន់បានដកប្រាក់)

កិច្ចសន្យាផ្តល់ឥណទាន (ឥណទាន និងបុរេប្រទានដែលមិនទាន់បានដកប្រាក់) ដែលធនាគារបានផ្តល់ ត្រូវបានវាស់វែងតាមចំនួនសំវិធានធនបាត់បង់។ ធនាគារមិនបានផ្តល់កិច្ចសន្យាផ្តល់ឥណទានណាមួយ ដែលមានអត្រាការប្រាក់ទាបជាងអត្រាទីផ្សារទេ ឬកិច្ចសន្យាដែលអាចត្រូវបានទូទាត់ជាសាច់ប្រាក់សុទ្ធ ឬតាមរយៈការផ្តល់ ឬការចេញឧបករណ៍ហិរញ្ញវត្ថុផ្សេងទៀតទេ។

ចំពោះកិច្ចសន្យាផ្តល់ឥណទាន (ឥណទាន និងបុរេប្រទានដែលមិនទាន់បានដកប្រាក់) ការខាតឥណទានរំពឹងទុកត្រូវបានកត់ត្រាជាសំវិធានធន (ដែលត្រូវបានដាក់បង្ហាញក្នុងបំណុលផ្សេងៗ)។ ទោះជាយ៉ាងណាក៏ដោយ ចំពោះកិច្ចសន្យាដែលរួមបញ្ចូលទាំងឥណទាន និងកិច្ចសន្យាដែលមិនទាន់ដកប្រាក់ ហើយដែលធនាគារមិនអាចកំណត់ការខាតឥណទានរំពឹងទុកដាច់ដោយឡែក ចំពោះកិច្ចសន្យាផ្តល់ឥណទានដែលមិនទាន់ដកប្រាក់ ត្រូវបានកត់ត្រារួមគ្នាក្នុងសំវិធានធនឥណទានបាត់បង់។ ក្នុងករណីដែលការខាតឥណទានរំពឹងទុករួមបញ្ចូលគ្នា លើសពីចំនួនតម្លៃយោងដុលរបស់ឥណទាន នោះការខាតឥណទានរំពឹងទុក ត្រូវបានកត់ត្រាជាសំវិធានធន។

## ២.៥ ការកាត់កងឧបករណ៍ហិរញ្ញវត្ថុ

ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយចំនួនទឹកប្រាក់សុទ្ធបន្ទាប់ពីកាត់កងត្រូវបានរាយការណ៍នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ នៅពេលដែលធនាគារមានសិទ្ធិតាមផ្លូវច្បាប់ក្នុងការកាត់កងចំនួនទឹកប្រាក់ដែលបានកត់ត្រា ហើយធនាគារមានបំណងនឹងទូទាត់តាមមូលដ្ឋានចំនួនទឹកប្រាក់សុទ្ធ ឬមានបំណងកត់ត្រាទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

## ២.៦ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

ក្នុងការដាក់បង្ហាញរបាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់និងសាច់ប្រាក់សមមូលរួមមាន សាច់ប្រាក់ក្នុងដៃ ប្រាក់បញ្ញើនិងការដាក់ប្រាក់មិនជាប់កម្រិតនៅធនាគារកណ្តាល ប្រាក់បញ្ញើនិងការដាក់ប្រាក់នៅធនាគារផ្សេងៗ និងការវិនិយោគសាច់ប្រាក់ងាយស្រួលរយៈពេលខ្លីដែលមានរយៈពេលកំណត់បីខែ ឬតិចជាងបីខែ ដែលធនាគារអាចមាន លទ្ធភាពពេញលេញក្នុងការដកសាច់ប្រាក់ ក្នុងគោលបំណងនៅពេលចាំបាច់ និងមានហានិភ័យបម្រែបម្រួលតម្លៃតិចតួច។

សមតុល្យនៅធនាគារត្រូវបានកត់ត្រាតាមថ្លៃដើមដករំលស់ ក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

**ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្ដីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៧ ទ្រព្យសម្បត្តិ និងបរិក្ខារ

ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកត់ត្រាថ្លៃដើម ដករំលស់។ ថ្លៃដើមរួមមានចំណាយផ្ទាល់ផ្សេងៗ ក្នុងការទិញទ្រព្យសកម្មនោះ។

ចំណាយបន្តបន្ទាប់ផ្សេងៗនៃខ្លួនទ្រព្យសម្បត្តិ និងបរិក្ខារណាមួយ ត្រូវបានកត់ត្រាបញ្ចូលទៅក្នុងតម្លៃយោងនៃទ្រព្យនោះ ឬត្រូវបានកត់ត្រាជាទ្រព្យសកម្មដាច់ដោយឡែក តាមការសមស្រប តែនៅពេលដែលមានភាពប្រាកដប្រជាថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតនៃទ្រព្យនោះនឹងហូរចូលមកក្នុងធនាគារ ហើយថ្លៃដើមនៃទ្រព្យនោះអាចត្រូវបានវាស់វែងគួរឱ្យជឿជាក់បានតែប៉ុណ្ណោះ។ ចំណាយលើការជួសជុល និងការថែទាំផ្សេងៗទៀតទាំងអស់ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងរបាយការណ៍ចំណេញ-ខាត ក្នុងឆ្នាំដែលប្រតិបត្តិការនោះបានកើតឡើង។

ដើមទុនកំពុងដំណើរការមិនត្រូវបានដករំលស់ទេ។ ការធ្វើរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានគណនាតាមវិធីសាស្ត្ររំលស់សមតុល្យថយចុះ លើកលែងតែការកែលម្អទ្រព្យជួល ដែលត្រូវបានដករំលស់តាមវិធីសាស្ត្ររំលស់ថេរ អាស្រ័យទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មានរបស់ទ្រព្យសកម្មនីមួយៗ ដូចខាងក្រោម៖

| **ចំណាត់ថ្នាក់** | **អត្រារំលស់** |
|---|---|
| ការកែលម្អទ្រព្យជួល | ៥ឆ្នាំ |
| បរិក្ខារការិយាល័យ | ៤ - ៥ឆ្នាំ |
| គ្រឿងសង្ហារិម និង បរិក្ខារបំពាក់ | ៤ - ៥ឆ្នាំ |
| បរិក្ខារកុំព្យូទ័រ | ២ឆ្នាំ |
| យានយន្ត | ៥ឆ្នាំ |

ការដករំលស់លើដើមទុនកំពុងដំណើរការ ចាប់ផ្ដើមនៅពេលវាមានភាពរួចរាល់សម្រាប់ការប្រើប្រាស់ទៅតាម បំណង។ អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យ និងកែសម្រួលតាមការសមស្រប នៅរៀងរាល់ដំណាច់ការិយបរិច្ឆេទរាយការណ៍នីមួយៗ។

តម្លៃយោងនៃទ្រព្យសកម្មណាមួយ ដែលលើសពីតម្លៃប៉ាន់ស្មានដែលអាចស្រង់មកវិញបានរបស់វា ត្រូវបានកត់ត្រាបន្ថយភ្លាមឱ្យនៅត្រឹមតម្លៃដែលអាចស្រង់មកវិញបាន។

ចំណេញ និងខាតពីការលក់ទ្រព្យសម្បត្តិ និងបរិក្ខារ ត្រូវបានកំណត់ដោយធ្វើការប្រៀបធៀបតម្លៃលក់បាន ជាមួយនឹងតម្លៃយោង និងត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាត។

### ២.៨ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបីរួមមាន អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ និងចំណាយពាក់ព័ន្ធ សម្រាប់ប្រព័ន្ធកម្មវិធីរបស់ធនាគារ។ វាត្រូវបានរាយការណ៍តាមថ្លៃដើមដករំលស់បង្គរ និងការខាតដែលបណ្ដាលមកពីការថយចុះតម្លៃ ប្រសិនបើ មាន។ អាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រដែលបានទិញ ត្រូវបានធ្វើមូលធនកម្មតាមមូលដ្ឋានថ្លៃដើម ដែលបានកើតឡើងដើម្បីទិញកម្មវិធីនោះមកប្រើប្រាស់។ ថ្លៃដើមទាំងនេះត្រូវបានដករំលស់ទៅតាមអាយុកាលប៉ាន់ស្មានរបស់វាក្នុងរយៈពេល១០ឆ្នាំ ដោយប្រើវិធីសាស្ត្ររំលស់ថេរ។

## ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.៩ ទ្រព្យសកម្មរយៈពេលវែងដែលត្រូវបានកាន់កាប់សម្រាប់លក់ចេញ

ទ្រព្យសកម្មរយៈពេលវែង (ទ្រព្យសម្បត្តិរឹបអូស) ត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មដែលត្រូវបានកាន់កាប់សម្រាប់លក់ចេញ ប្រសិនបើតម្លៃយោងរបស់វាអាចស្រង់មកវិញបាន ជាពិសេសតាមរយៈការលក់ចេញ ជាជាងតាមរយៈការបន្តការប្រើប្រាស់ ហើយការលក់ចេញនោះត្រូវបានចាត់ទុកថាមានលទ្ធភាពខ្ពស់។ វាត្រូវបានវាស់វែងតាមតម្លៃណាមួយដែលទាបជាងគេរវាង តម្លៃយោងរបស់វា និងតម្លៃសមស្របដកចំណាយក្នុងការលក់។

ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រានៅពេលកត់ត្រាបន្ថយទ្រព្យសកម្មនោះលើកដំបូង ឬនៅពេលបន្ទាប់មក ឱ្យនៅត្រឹមតម្លៃសមស្របដកចំណាយក្នុងការលក់របស់ទ្រព្យនោះ ប៉ុន្តែមិនត្រូវលើសពីការខាតបង្គរដែលបណ្តាលមកពីការថយចុះតម្លៃណាមួយ ដែលត្រូវបានកត់ត្រាក្នុងគ្រាមុនរួចហើយទេ។ ចំណេញឬខាត ដែលមិនត្រូវបានកត់ត្រាក្នុងគ្រាមុន នាកាលបរិច្ឆេទលក់ទ្រព្យសកម្មរយៈពេលវែងនោះចេញ ត្រូវបានកត់ត្រានាកាលបរិច្ឆេទឈប់កត់ត្រានោះ។

ទ្រព្យសកម្មរយៈពេលវែងមិនត្រូវបានដករំលស់ទេ នៅពេលដែលវាត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មដែលត្រូវបានកាន់កាប់សម្រាប់លក់ចេញ។

ទ្រព្យសកម្មរយៈពេលវែងដែលត្រូវបានចាត់ថ្នាក់ជាទ្រព្យសកម្មដែលត្រូវបានកាន់កាប់សម្រាប់លក់ចេញ ត្រូវបានដាក់បង្ហាញដាច់ដោយឡែកពីទ្រព្យសកម្មផ្សេងៗ ក្នុងតារាងតុល្យការ។

### ២.១០ ការថយចុះតម្លៃ នៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ទ្រព្យសកម្មទាំងឡាយណាដែលមានអាយុកាលប្រើប្រាស់មិនកំណត់ មិនត្រូវបានដករំលស់ទេ ហើយវាត្រូវបានត្រួតពិនិត្យប្រចាំឆ្នាំ ដើម្បីរកការថយចុះតម្លៃរបស់វា។ ទ្រព្យសកម្មទាំងឡាយណាដែលត្រូវដករំលស់ ត្រូវបានត្រួតពិនិត្យរកការថយចុះរបស់វា នៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈណាមួយចង្អុលបង្ហាញថាតម្លៃយោងរបស់វានឹងមិនអាចស្រង់មកវិញបាន។ ការខាតបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាតាមចំនួនលម្អៀងរវាងតម្លៃយោងដែលលើសពីតម្លៃដែលអាចស្រង់មកវិញបានរបស់ទ្រព្យនោះ។ តម្លៃដែលអាចស្រង់មកវិញបាន គឺជាតម្លៃមួយណា ដែលខ្ពស់ជាងគេ រវាងតម្លៃសមស្របនៃទ្រព្យនោះ ដកចំណាយក្នុងការលក់ និងតម្លៃនៅប្រើប្រាស់។ ក្នុងការប៉ាន់ស្មានរកការថយចុះតម្លៃ ទ្រព្យសកម្មត្រូវបានដាក់ជាក្រុមតូចៗបំផុត ដែលគេអាចកំណត់លំហូរសាច់ប្រាក់របស់វាដាច់ដោយឡែកពីគ្នា ដែលវាមានឯករាជ្យទាំងស្រុងពីលំហូរសាច់ប្រាក់ចូលរបស់ទ្រព្យសកម្ម ឬក្រុមទ្រព្យសកម្មដទៃ (ក្រុមបង្កើតសាច់ប្រាក់)។ ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុដែលមានការថយចុះតម្លៃ ក្រៅពីកេរ្តិ៍ឈ្មោះអាជីវកម្ម ត្រូវបានត្រួតពិនិត្យរកមើលលទ្ធភាពដើម្បី កត់ត្រាការថយចុះតម្លៃត្រឡប់ទៅវិញ នៅរៀងរាល់ដំណាច់ការិយបរិច្ឆេទរាយការណ៍នីមួយៗ។

ការខាតដែលបណ្តាលមកពីការថយចុះតម្លៃ ត្រូវបានកត់ត្រាជាបន្ទុកនៅក្នុងចំណេញ-ខាត ក្នុងឆ្នាំដែលវាបានកើតឡើង។ ការកត់ត្រាការខាតដែលបណ្តាលមកពីការថយចុះតម្លៃត្រលប់មកវិញ ត្រូវបានកត់ត្រានៅក្នុងចំណេញ-ខាតទៅតាមចំនួនតម្លៃយោងរបស់ទ្រព្យសកម្ម ដែលមិនលើសពីតម្លៃយោងដែលត្រូវបានកំណត់រួច កាត់កងជាមួយនឹងរំលស់ទ្រព្យសម្បត្តិ និងបរិក្ខារ និងរំលស់ទ្រព្យសកម្មអរូបី ប្រសិនបើមិនបានកត់ត្រាការខាតដែលបណ្តាលមកពីការថយចុះតម្លៃ។

**ធនាគារ ឯកទេស ខេមរា ដេវេឡុបមេន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

## ២.១១ ភតិសន្យា

<u>ក្រុមហ៊ុនជាភាគីអ្នកជួល</u>

នៅពេលចាប់ផ្តើមកិច្ចសន្យា ធនាគារវាយតម្លៃថាតើកិច្ចសន្យានោះ ឬខ្លឹមសាររបស់វាជាភតិសន្យាដែរឬទេ។ កិច្ចសន្យាមួយ ឬ ខ្លឹមសារនៃកិច្ចសន្យាមួយ ត្រូវបានចាត់ទុកថាជាភតិសន្យាប្រសិនបើកិច្ចសន្យានោះផ្តល់សិទ្ធិក្នុងការគ្រប់គ្រងការប្រើប្រាស់ទ្រព្យសកម្មដែលត្រូវបានកំណត់មួយ ក្នុងរយៈពេលណាមួយ ជាថ្នូរនឹងការបង់ប្រាក់។

កិច្ចសន្យាអាចមានទាំងធាតុភតិសន្យា និងធាតុមិនមែនភតិសន្យា។ ធនាគារបានបែងចែកសាច់ប្រាក់ក្នុងកិច្ចសន្យា ជាធាតុភតិសន្យា និងធាតុមិនមែនភតិសន្យា អាស្រ័យទៅតាមថ្លៃឈ្នួលពាក់ព័ន្ធរបស់វា។

ថិរវេលានៃភតិសន្យាត្រូវបានចរចាតាមមូលដ្ឋានភតិសន្យានីមួយៗ ហើយវាមានលក្ខខណ្ឌផ្សេងៗមួយចំនួនខុសប្លែកពីគ្នា។ កិច្ចព្រមព្រៀងភតិសន្យាមិនតម្រូវឱ្យមានកិច្ចសន្យាផ្លូវច្បាប់ណាផ្សេងទៀត ក្រៅពីអត្ថប្រយោជន៍ធានា ផ្សេងៗ នៅក្នុងទ្រព្យសកម្មភតិសន្យាដែលត្រូវបានកាន់កាប់ដោយភាគីម្ចាស់ទ្រព្យនោះទេ។ ទ្រព្យសកម្មដែលត្រូវបានជួល អាចមិនត្រូវបានប្រើប្រាស់ជាទ្រព្យបញ្ចាំ សម្រាប់ការខ្ចីប្រាក់ទេ។

ភតិសន្យាត្រូវបានកត់ត្រាជាទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ និងជាបំណុលពាក់ព័ន្ធ នាកាលបរិច្ឆេទដែលទ្រព្យសកម្មដែលបានជួល មានភាពរួចរាល់សម្រាប់ប្រើប្រាស់។

ទ្រព្យសកម្ម និងបំណុលដែលកើតពីភតិសន្យា ត្រូវបានកត់ត្រាជាដំបូងតាមមូលដ្ឋានតម្លៃបច្ចុប្បន្ន។

(i) បំណុលភតិសន្យា

បំណុលភតិសន្យារួមបញ្ចូលនូវតម្លៃបច្ចុប្បន្នសុទ្ធនៃការទូទាត់ភតិសន្យាថេរ (រួមទាំង ការបង់ប្រាក់ថេរផ្សេងៗ) ដកនឹងការលើកទឹកចិត្តផ្សេងៗសម្រាប់ការជួលដែលត្រូវទទួលបាន។

ការទូទាត់ភតិសន្យាដែលត្រូវធ្វើឡើងក្រោមជម្រើសដែលអាចពន្យាររយៈពេលបាន ប្រកបដោយភាពសមហេតុផល មិនត្រូវបានរួមបញ្ចូលនៅក្នុងការវាស់វែងបំណុលទេ។

ការទូទាត់ភតិសន្យាត្រូវបានធ្វើអប្បហារ ដោយប្រើអត្រាក្នុងភតិសន្យានោះ។ ប្រសិនបើអត្រានោះមិនទាន់ត្រូវបានកំណត់រួចរាល់ នោះអត្រាកំណើនប្រាក់កម្ចីរបស់ភាគីអ្នកជួល នឹងត្រូវបានប្រើប្រាស់ជំនួសវិញ ដែលវាជាអត្រាប្រហាក់ប្រហែលនឹងចំណាយប្រាក់កម្ចីមធ្យមនាកាលបរិច្ឆេទនោះ ហើយវាគឺជាអត្រាដែលភាគីអ្នកជួលនីមួយៗត្រូវចំណាយ ដើម្បីទទួលបានប្រាក់កម្ចី ដែលមានភាពចាំបាច់ដើម្បីទទួលបានទ្រព្យសកម្មដែលមានតម្លៃប្រហាក់ប្រហែលនឹងទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ នៅក្នុងបរិយាកាសសេដ្ឋកិច្ចស្រដៀងគ្នា ជាមួយនឹងលក្ខខណ្ឌ និងការធានាប្រហាក់ប្រហែលគ្នា។

ដើម្បីកំណត់អត្រាកំណើនប្រាក់កម្ចី ធនាគារប្រើប្រាស់អត្រាប្រាក់កម្ចីចុងក្រោយគេរបស់ខ្លួន ជាចំណុចចាប់ផ្តើមដោយធ្វើការកែតម្រូវជាក់លាក់ទៅតាមភតិសន្យានោះ។

ការទូទាត់ភតិសន្យាត្រូវបានបែងចែករវាងប្រាក់ដើម និងចំណាយការប្រាក់។ ចំណាយការប្រាក់ត្រូវបានកត់ត្រាជាបន្ទុកក្នុងចំណេញ-ខាត ក្នុងរយៈពេលនៃភតិសន្យានោះ ដើម្បីបង្កើតអត្រាការប្រាក់ថេរតាមកាលកំណត់មួយ លើចំនួនសមតុល្យបំណុលដែលនៅសល់ ក្នុងការិយបរិច្ឆេទនីមួយៗ។

**ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១១ ភតិសន្យា (ត)

(ii) ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់

ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ត្រូវបានកត់ត្រាលើកដំបូងតាមថ្លៃដើម ដែលរួមមាន៖

- ចំនួនទឹកប្រាក់នៃបំណុលភតិសន្យាដែលបានវាស់វែងលើកដំបូង
- ចំណាយក្នុងការជួសជុលឡើងវិញ ប្រសិនបើមាន
- ការទូទាត់ភតិសន្យាណាមួយដែលបានធ្វើឡើងនៅកាលបរិច្ឆេទចាប់ផ្តើម ឬមុនកាលបរិច្ឆេទចាប់ផ្តើម ដកការលើកទឹកចិត្តផ្សេងៗដែលទទួលបានពីការជួល
- ចំណាយផ្ទាល់លើកដំបូង

ជាទូទៅ ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ ត្រូវបានដករំលស់តាមមូលដ្ឋានរំលស់ថេរ លើរយៈពេលណាមួយដែលខ្លីជាងគេរវាង អាយុកាលប្រើប្រាស់របស់ទ្រព្យសកម្ម និងរយៈពេលជួល។ ប្រសិនបើធនាគារមានបំណងជាក់លាក់ដ៏សមហេតុផលក្នុងការទិញ នោះទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់នោះត្រូវបានដករំលស់ លើអាយុកាលប្រើប្រាស់ មូលដ្ឋានរបស់ទ្រព្យសកម្មនោះ។

បន្ទាប់មកទៀត ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ ត្រូវបានវាស់វែងតាមថ្លៃដើមដករំលស់ និងការខាតដែលបណ្តាលមកពីការថយចុះតម្លៃបង្គរ ប្រសិនបើមាន។

(iii) ការទូទាត់ភតិសន្យាក្រោមការលើកលែងផ្សេងៗ

ការទូទាត់នានាដែលពាក់ព័ន្ធនឹងភតិសន្យាដែលមានរយៈពេលខ្លី និងភតិសន្យាទាំងអស់ដែលមានតម្លៃទាបត្រូវបានកត់ត្រាជាចំណាយតាមមូលដ្ឋានថេរនៅក្នុងចំណេញ-ខាត។ ភតិសន្យាដែលមានរយៈពេលខ្លី គឺជាភតិសន្យាទាំងឡាយណាដែលមានថិរវេលាជួល១២ខែ ឬខ្លីជាងនេះ។ ទ្រព្យសកម្មដែលមានតម្លៃទាបរួមមាន ខ្ទង់តូចៗនៃគ្រឿងសង្ហារិមក្នុងការិយាល័យ។

### ២.១២ សំវិធានធន

សំវិធានធនត្រូវបានកត់ត្រា នៅពេលដែលធនាគារមានកាតព្វកិច្ចតាមផ្លូវច្បាប់នាពេលបច្ចុប្បន្ន ឬ កាតព្វកិច្ចប្រយោលដែលជាលទ្ធផលនៃព្រឹត្តិការណ៍ពីអតីតកាល ដែលទំនងជាអាចតម្រូវឱ្យមានការចំណាយធនធានដើម្បីទូទាត់កាតព្វកិច្ចនោះ ហើយចំនួនទឹកប្រាក់ត្រូវបានប៉ាន់ស្មានគួរឱ្យជឿជាក់បាន។ សំវិធានធនមិនត្រូវបានកត់ត្រាសម្រាប់ការខាតបង់ពីប្រតិបត្តិការនាពេលអនាគតទេ។

សំវិធានធនត្រូវបានវាស់វែងតាមតម្លៃបច្ចុប្បន្ននៃចំណាយដែលរំពឹងថាត្រូវទូទាត់កាតព្វកិច្ចនោះ ដោយប្រើអត្រាមុនបង់ពន្ធ ដើម្បីឆ្លុះបញ្ចាំងអំពីការវាយតម្លៃទីផ្សារបច្ចុប្បន្ននៃតម្លៃសាច់ប្រាក់គិតតាមពេលវេលា និងហានិភ័យជាក់លាក់ផ្សេងៗនៃកាតព្វកិច្ចនោះ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលាដែលបានកន្លងផុត ត្រូវបានកត់ត្រាជាចំណាយការប្រាក់។

**ធនាគារ ឯកទេស ខេមឺ ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៣ ពន្ធលើប្រាក់ចំណូលក្នុងគ្រា និងពន្ធពន្យារលើប្រាក់ចំណូល

ចំណាយពន្ធលើប្រាក់ចំណូល ឬឥណទានពន្ធក្នុងការិយបរិច្ឆេទ គឺជាប្រាក់ពន្ធត្រូវបង់ចំពោះប្រាក់ចំណូលជាប់ពន្ធក្នុងការិយបរិច្ឆេទ អាស្រ័យទៅតាមអត្រាពន្ធលើប្រាក់ចំណូលដែលនៅជាធរមាន ហើយត្រូវបានកែតម្រូវទៅតាមបម្រែបម្រួលពន្ធពន្យារទ្រព្យសកម្ម និងបំណុលពន្ធពន្យារ ដែលបណ្តាលមកពីលម្អៀងបណ្តោះអាសន្ន។

បន្ទុកពន្ធលើប្រាក់ចំណូលក្នុងគ្រា ត្រូវបានគណនាតាមមូលដ្ឋានច្បាប់សារពើពន្ធ ដែលបានអនុម័តជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ គិតត្រឹមកាលបរិច្ឆេទរាយការណ៍ នៅក្នុងប្រទេសដែលធនាគារធ្វើប្រតិបត្តិការ និងបង្កើតប្រាក់ចំណូលជាប់ពន្ធ។ គណៈគ្រប់គ្រងវាយតម្លៃអំពីស្ថានភាពដែលបានប្រកាសពន្ធ ជាមួយនឹងស្ថានភាពនៃបទប្បញ្ញត្តិពន្ធ។ ធនាគារកត់ត្រាសំវិធានធនទៅតាមភាពសមស្រប អាស្រ័យទៅតាមមូលដ្ឋាននៃចំនួនប្រាក់ពន្ធ ដែលធនាគាររំពឹងថាត្រូវបង់ជូនអាជ្ញាធរពន្ធដារ។

ពន្ធពន្យារលើប្រាក់ចំណូលត្រូវបានកត់ត្រាពេញលេញ ដោយប្រើវិធីសាស្ត្របំណុល ទៅលើចំនួនលម្អៀង បណ្តោះអាសន្នដែលកើតមានឡើង រវាងមូលដ្ឋានពន្ធនៃទ្រព្យសកម្ម និងបំណុល និងតម្លៃយោងរបស់វានៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។ ពន្ធពន្យារលើប្រាក់ចំណូលត្រូវបានកំណត់ដោយប្រើអត្រា ដែលត្រូវបានអនុម័តជាស្ថាពរ ឬបានអនុម័តរួចមួយផ្នែកធំ នាកាលបរិច្ឆេទរាយការណ៍ និងត្រូវបានរំពឹងថាត្រូវអនុវត្តនៅពេលដែលពន្ធពន្យារទ្រព្យសកម្មពាក់ព័ន្ធត្រូវបានកត់ត្រា ឬបំណុលពន្ធពន្យារលើប្រាក់ចំណូលត្រូវបានទូទាត់។

ពន្ធពន្យារទ្រព្យសកម្មត្រូវបានកត់ត្រា លុះត្រាតែមានភាពប្រាកដថាធនាគារនឹងមានប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត ដើម្បីអាចប្រើប្រាស់លម្អៀងបណ្តោះអាសន្ន និងការខាតតែប៉ុណ្ណោះ។

ពន្ធពន្យារទ្រព្យសកម្ម និងបំណុលពន្ធពន្យារត្រូវបានកាត់កង នៅពេលដែលធនាគារមានសិទ្ធិតាមផ្លូវច្បាប់ ដើម្បីកាត់កងពន្ធទ្រព្យសកម្មក្នុងគ្រា ជាមួយនឹងបំណុលពន្ធក្នុងគ្រា និងនៅពេលដែលសមតុល្យពន្ធពន្យារ ពាក់ព័ន្ធទៅនឹងអាជ្ញាធរពន្ធដូចគ្នា។ ពន្ធពន្យារទ្រព្យសកម្ម និងបំណុលពន្ធពន្យារត្រូវបានកាត់កង នៅពេលដែលធនាគារមានសិទ្ធិតាមផ្លូវច្បាប់ និងមានបំណងទូទាត់តាមមូលដ្ឋានចំនួនទឹកប្រាក់សុទ្ធ ឬកត់ត្រាទ្រព្យសកម្ម និងទូទាត់បំណុលក្នុងពេលដំណាលគ្នា។

ពន្ធក្នុងគ្រា និងពន្ធពន្យារត្រូវបានកត់ត្រាក្នុងចំណេញ-ខាត លើកលែងតែវាពាក់ព័ន្ធនឹងខ្ទង់ទាំងឡាយណាដែលត្រូវបានកត់ត្រាក្នុងលទ្ធផលលម្អិតផ្សេងៗ ឬខ្ទង់ដែលត្រូវបានកត់ត្រាផ្ទាល់ក្នុងមូលធន។ ក្នុងករណីនេះ ពន្ធក៏ត្រូវបានកត់ត្រាក្នុងលទ្ធផលលម្អិតផ្សេងៗ ឬក្នុងមូលធនដែរ។

### ២.១៤ ដើមទុន

ដើមទុនត្រូវបានចាត់ថ្នាក់ជាមូលធន។ ចំណាយបន្ថែមដែលបានចំណាយផ្ទាល់ក្នុងការចេញផ្សាយភាគហ៊ុនថ្មីត្រូវបានដាក់បង្ហាញក្នុងមូលធន ដោយកាត់បន្ថយពីសាច់ប្រាក់បានទទួល និងកាត់កងជាមួយពន្ធ។

## ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៥ ទុនបម្រុងតាមច្បាប់

ធនាគារ និងគ្រឹះស្ថានហិរញ្ញវត្ថុត្រូវបានតម្រូវឱ្យគណនាសំវិធានធនតាមច្បាប់ អនុលោមទៅតាមប្រកាសលេខ ធ៧-០១៧-៣៤៤ប្រ.ក ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ និងសារាចរណែនាំលេខ ធ៧-០១៨-០០១ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពី "ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអឹមកែរមិន"។ ប្រសិនបើសំវិធានធនតាមច្បាប់បង្គរមានចំនួនខ្ពស់ជាងការថយចុះតម្លៃបង្គរផ្អែកតាម CIFRS 9 នោះ 'ការបំពេញបន្ថែម - topping up' នឹងត្រូវបានកត់ត្រាជាទុនបម្រុងតាមច្បាប់ និងត្រូវបានដាក់បង្ហាញនៅក្នុងមូលធន។ បន្ទាប់មក ទុនបម្រុងត្រូវបានកត់ត្រាត្រឡប់ទៅវិញ (រហូតដល់សូន្យ) ប្រសិនបើសំវិធានធនតាមច្បាប់បង្គរ មានចំនួនស្មើគ្នា ឬ ទាបជាងការថយចុះតម្លៃបង្គរដែលផ្អែកតាម CIFRS 9។ ទុនបម្រុងតាមច្បាប់ត្រូវបានតម្កល់ទុកមួយឡែក ជាទ្រនាប់ដើមទុន ហើយមិនអាចបែងចែកបាន និងមិនត្រូវបានអនុញ្ញាតឱ្យរួមបញ្ចូលនៅក្នុងការគណនាមូលនិធិផ្ទាល់សុទ្ធទេ។

### ២.១៦ អត្ថប្រយោជន៍បុគ្គលិក

(i) អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី

អត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លីត្រូវបានកត់ត្រាបង្គរ ក្នុងឆ្នាំដែលបុគ្គលិកបានបម្រើការងារឱ្យធនាគារ។

(ii) អត្ថប្រយោជន៍បុគ្គលិករយៈពេលវែងផ្សេងៗ - ការទូទាត់ប្រាក់បំណាច់អតីតភាពការងារ

នៅខែមិថុនា ឆ្នាំ២០១៨ រាជរដ្ឋាភិបាលកម្ពុជាបានធ្វើវិសោធនកម្មលើច្បាប់ស្តីពីការងារ ដែលណែនាំពីគម្រោងការទូទាត់ប្រាក់បំណាច់អតីតភាពការងារ។ បន្ទាប់មកនៅថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១៨ ប្រកាសលេខ ៤៤៣ K.B/Br.K.Kh.L ត្រូវបានចេញផ្សាយ ដោយបានផ្តល់នូវគោលការណ៍ណែនាំស្តីពីការអនុវត្តច្បាប់នេះ។ អនុលោមទៅតាមច្បាប់/ប្រកាស តម្រូវឱ្យអង្គភាពនីមួយៗទូទាត់ប្រាក់បំណាច់អតីតភាពការងារឱ្យនិយោជិត ដែលមានកិច្ចសន្យាការងារមិនមានរយៈពេលកំណត់ ដូចខាងក្រោម៖

- ប្រាក់បំណាច់ការងារប្រចាំឆ្នាំ - ចូលជាធរមានក្នុងខែមករា ឆ្នាំ២០១៩ - ស្មើនឹង ១៥ ថ្ងៃ នៃប្រាក់បៀវត្សរ៍ប្រចាំខែរបស់បុគ្គលិក និងអត្ថប្រយោជន៍ក្នុងឆ្នាំនីមួយៗគិតជាមធ្យម ដែលត្រូវទូទាត់រៀងរាល់ ៦ ខែម្តង នៅថ្ងៃទី៣០ ខែមិថុនា និងថ្ងៃទី៣១ ខែធ្នូ (៧.៥ ថ្ងៃ ក្នុងការទូទាត់ម្តងៗ)។

- ការបើករំឭកប្រាក់បំណាច់អតីតភាពការងារ - និយោជិតមានសិទ្ធិទទួលបានការបើករំឭកប្រាក់បំណាច់អតីតភាពការងារ ស្មើនឹង១៥ថ្ងៃនៃប្រាក់បៀវត្សរ៍របស់ពួកគេក្នុងមួយឆ្នាំ គិតចាប់តាំងពីថ្ងៃចូលបម្រើការងាររហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ហើយនៅតែបន្តការងារជាមួយធនាគារ។ ការបើករំឭកប្រាក់បំណាច់អតីតភាពការងារអាស្រ័យទៅតាមចំនួនឆ្នាំអតីតភាពការងាររបស់បុគ្គលិកម្នាក់ៗ ហើយមិនត្រូវលើសពី៦ខែនៃប្រាក់បៀវត្សរ៍ដុលមធ្យមទេ។ នៅថ្ងៃទី២២ ខែមីនា ឆ្នាំ២០១៩ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានចេញសេចក្តីណែនាំលេខ ០៤២/១៩ K.B/S.N.N.Kh.L ដើម្បីពន្យារពេលការបើករំឭកប្រាក់បំណាច់អតីតភាពការងារ ដែលនឹងត្រូវទូទាត់ឱ្យចំនួនបីថ្ងៃ ក្នុងខែមិថុនា និងខែធ្នូ ចាប់ផ្តើមនៅខែធ្នូ ឆ្នាំ២០២១។

**ធនាគារ ឯកទេស ខេមី ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៦ អត្ថប្រយោជន៍បុគ្គលិក (ត)

ការទូទាត់ប្រាក់បំណាច់ការងារប្រចាំឆ្នាំ ត្រូវបានចាត់ទុកថាជាអត្ថប្រយោជន៍បុគ្គលិករយៈពេលខ្លី ហើយវាត្រូវបានកត់ត្រាបង្គរក្នុងឆ្នាំដែលបុគ្គលិកបានបម្រើការងារឱ្យធនាគារ។

ធនាគារបានព្រមព្រៀងបង់ប្រាក់បំណាច់អតីតភាពការងារខាងលើឱ្យបុគ្គលិករបស់ខ្លួន ក្នុងឆ្នាំ២០១៨ ដូចនេះ ធនាគារមិនមានសំវិធានធនសម្រាប់កាតព្វកិច្ចការបើកំរំពួកប្រាក់បំណាច់អតីតភាពការងារ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ ទេ។

### ២.១៧ ចំណូល និងចំណាយការប្រាក់

ចំណូលនិងចំណាយការប្រាក់ពីឧបករណ៍ហិរញ្ញវត្ថុ ដែលវាស់វែងតាមថ្លៃដើមដករំលស់ ត្រូវបានកត់ត្រាក្នុង "ចំណូលការប្រាក់" និង "ចំណាយការប្រាក់" ក្នុងរបាយការណ៍ចំណេញ-ខាត ដោយប្រើវិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព។

វិធីសាស្ត្រការប្រាក់មានប្រសិទ្ធភាព គឺជាវិធីសាស្ត្រក្នុងការគណនាថ្លៃដើមដករំលស់នៃទ្រព្យសកម្មហិរញ្ញវត្ថុមួយ ឬបំណុលហិរញ្ញវត្ថុមួយ និងជាវិធីសាស្ត្រក្នុងការបែងចែកចំណូលការប្រាក់ ឬចំណាយការប្រាក់ លើរយៈពេលដែលពាក់ព័ន្ធ។ អត្រាការប្រាក់មានប្រសិទ្ធភាពគឺជាអត្រា ដែលធ្វើអប្បហារជាក់ស្តែងចំពោះការទូទាត់សាច់ប្រាក់នាពេលអនាគត ប៉ាន់ស្មាន ឬបង្កាន់ដៃទទួលប្រាក់ ក្នុងរយៈពេលនៃអាយុកាលប៉ាន់ស្មានរបស់ឧបករណ៍ហិរញ្ញវត្ថុ ឬក្នុងរយៈពេលណាមួយដែលខ្លីជាងទៅតាមការសមស្រប ចំពោះតម្លៃយោងសុទ្ធរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។ នៅពេលគណនាអត្រាការប្រាក់មានប្រសិទ្ធភាព ធនាគារបានកត់ត្រារាល់លក្ខខណ្ឌក្នុងកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ និងបានរួមបញ្ចូលនូវកម្រៃ ឬកំណើនចំណាយនានា ដែលបានចំណាយដោយផ្ទាល់ចំពោះឧបករណ៍មួយ ហើយវាជាផ្នែកមួយនៃអត្រាការប្រាក់មានប្រសិទ្ធភាព ប៉ុន្តែមិនមែនជាការខាតឥណទាននាពេលអនាគតទេ។

ចំណូលការប្រាក់ត្រូវបានគណនាដោយអនុវត្តអត្រាការប្រាក់មានប្រសិទ្ធភាព ចំពោះតម្លៃយោងដុលរបស់ទ្រព្យសកម្មហិរញ្ញវត្ថុ លើកលែងតែចំពោះ៖

- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមានការថយចុះតម្លៃដែលបានទិញ ឬបានបង្កើតឡើង ("POCI") ដែលអត្រាការប្រាក់មានប្រសិទ្ធភាពសម្រាប់កែតម្រូវឥណទានលើកដំបូង ត្រូវបានអនុវត្តចំពោះថ្លៃដើមដករំលស់របស់ទ្រព្យសកម្មហិរញ្ញវត្ថុ។
- ទ្រព្យសកម្មហិរញ្ញវត្ថុដែលមិនមែនជា POCI ប៉ុន្តែបានក្លាយជាឥណទានដែលមានការថយចុះតម្លៃមួយផ្នែកធំ (ឬ "ដំណាក់កាលទី ៣") ដែលចំណូលការប្រាក់ត្រូវបានគណនាដោយប្រើអត្រាការប្រាក់មានប្រសិទ្ធភាពចំពោះថ្លៃដើមដករំលស់របស់វា (ឧ. កាត់កងជាមួយនឹងសំវិធានធនការខាតឥណទានរំពឹងទុក)។

**ធនាគារ ឯកទេស ខេមរា ដេហាន ម.ក**

**កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩**

## ២. សេចក្តីសង្ខេបអំពីគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### ២.១៨ ចំណូលកម្រៃជើងសារ

ចំណូលកម្រៃជើងសារត្រូវបានកត់ត្រាជាចំណូល នៅពេលដែលវាបានបំពេញតាមគំរូលក្ខខណ្ឌទាំងអស់ (កាតព្វកិច្ចនៃដំណើរការត្រូវបានទទួលយក ហើយការគ្រប់គ្រងត្រូវបានផ្ទេរទៅតាមសមមាត្រនៃសេវាដែលបានបំពេញ ឬពេលទទួលបានកម្រៃសេវា។

កម្រៃក្នុងដំណើរការផ្តល់ឥណទាន បុរេប្រទាន និងហិរញ្ញប្បទាន ដែលទំនងជាអាចត្រូវបានផ្តល់ឱ្យ ត្រូវបានពន្យារ (ជាមួយនឹងចំណាយផ្ទាល់ពាក់ព័ន្ធ) ហើយចំណូលដែលជាផ្នែកនៃអត្រាការប្រាក់មានប្រសិទ្ធភាពរបស់ឧបករណ៍ហិរញ្ញវត្ថុមួយ ត្រូវបានកត់ត្រាដោយធ្វើនិយ័តកម្មទៅលើអត្រាការប្រាក់មានប្រសិទ្ធភាពរបស់ឧបករណ៍ហិរញ្ញវត្ថុនោះ។

### ២.១៩ តួលេខបង្គត់

ចំនួនទឹកប្រាក់ជាប្រាក់ដុល្លារអាមេរិកទាំងអស់ ដែលត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សម្គាល់ផ្សេងៗ គឺជាចំនួនទឹកប្រាក់ទាំងស្រុង។

ចំនួនទឹកប្រាក់ជាប្រាក់រៀលទាំងអស់ ដែលត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងកំណត់សម្គាល់ផ្សេងៗ ត្រូវបានកាត់ខ្ទង់បង្គត់ខ្ទង់ពាន់ លើកលែងតែមានការបញ្ជាក់ផ្សេងពីនេះ។

## ៣. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ធនាគារធ្វើការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ដែលមានផលប៉ះពាល់ដល់ចំនួនទឹកប្រាក់ទ្រព្យសកម្ម និងបំណុលដែលបានរាយការណ៍។ ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យ ត្រូវបានវាយតម្លៃជាបន្តបន្ទាប់ ដោយផ្អែកទៅតាមបទពិសោធន៍ក្នុងគ្រាកន្លងមក និងកត្តាផ្សេងៗទៀត រួមទាំង ការរំពឹងទុកអំពីព្រឹត្តិការណ៍នាពេលអនាគត ដែលគេជឿជាក់ថាមានភាពសមហេតុផល ទៅតាមកាលៈទេសៈផ្សេងៗ។

(ក) ការវាស់វែងសំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក

ការវាស់វែងសំវិធានធនសម្រាប់ការខាតឥណទានរំពឹងទុក ចំពោះទ្រព្យសកម្មហិរញ្ញវត្ថុដែលវាស់វែងតាមថ្លៃដើមដករំលស់ តម្រូវឱ្យប្រើប្រាស់គំរូស្មុគស្មាញ និងការសន្មតជាក់លាក់ ចំពោះលក្ខខណ្ឌសេដ្ឋកិច្ចនាពេលអនាគត និង លក្ខណៈរបស់ឥណទាន (ឧ. លទ្ធភាពដែលអតិថិជនអាចមិនសងប្រាក់ និងបណ្តាលឱ្យមានការខាតបង់)។

ការវិនិច្ឆ័យជាក់លាក់មួយចំនួន ក៏ត្រូវបានតម្រូវនៅក្នុងការអនុវត្តតម្រូវការគណនេយ្យសម្រាប់ការវាស់វែង ECL ផងដែរ ដូចជា៖

- ការកំណត់លក្ខណៈវិនិច្ឆ័យចំពោះកំណើនហានិភ័យឥណទានជាក់លាក់
- ជ្រើសរើសគំរូ និងការសន្មតសមស្រប សម្រាប់ការវាស់វែង ECL
- ការបង្កើតចំនួនសេណារីយ៉ូ និងការថ្លឹងពាក់ព័ន្ធ សម្រាប់ពេលអនាគត ចំពោះប្រភេទនៃផលិតផលនីមួយៗ និង ECL ដែលពាក់ព័ន្ធ និង
- ការបង្កើតក្រុមទ្រព្យសកម្មហិរញ្ញវត្ថុដែលមានលក្ខណៈស្រដៀងគ្នា ក្នុងគោលបំណងដើម្បីវាស់វែង ECL

## ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ៤. ការផ្ទេរមកអនុវត្ត CIFRS

របាយការណ៍ហិរញ្ញវត្ថុរបស់ធនាគារសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩ គឺជារបាយការណ៍ហិរញ្ញវត្ថុដំបូង ដែលត្រូវបានរៀបចំឡើងតាម CIFRS ។

រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ ធនាគារបានរៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយអនុលោមទៅតាមគោលការណ៍ណែនាំដែលចេញផ្សាយដោយធនាគារជាតិ នៃ កម្ពុជា (ហៅកាត់ថា "ធនាគារកណ្តាល") និងស្តង់ដារគណនេយ្យកម្ពុជា (ហៅកាត់ថា "CAS") ។ ក្នុងការផ្លាស់ប្តូរមកអនុវត្ត CIFRS ធនាគារបានរៀបចំ និងបានបង្ហាញរបាយការណ៍ ហិរញ្ញវត្ថុដូចខាងក្រោម ទៅតាម CIFRS ៖

- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨
- របាយការណ៍ស្ថានភាពហិរញ្ញវត្ថុដើមគ្រា គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨
- របាយការណ៍ចំណេញ-ខាត និងលទ្ធផលលម្អិតផ្សេងៗ សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨
- របាយការណ៍បម្រែបម្រួលមូលធន សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

កំណត់សម្គាល់នេះបង្ហាញពីការផ្ទៀងផ្ទាត់មូលធន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និងថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ និងការផ្ទៀងផ្ទាត់លទ្ធផលលម្អិតសរុបសម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨។

ក្នុងការអនុវត្ត CIFRS លើកដំបូង ធនាគារបានអនុវត្តការលើកលែងសំខាន់ៗដែលអាចអនុវត្តបាន និងការលើកលែងដែលអាចជ្រើសរើសបាន ចំពោះការអនុវត្តត្រឡប់ក្រោយ ដូចខាងក្រោម៖

<u>ការលើកលែងសំខាន់ៗដែលអាចអនុវត្តបានចំពោះធនាគារ</u>

- ការប៉ាន់ស្មានគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨ និង ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ អនុលោមទៅតាម CIFRS ដែលមានសង្គតិភាពជាមួយនឹងការប៉ាន់ស្មានទាំងឡាយណា ដែលត្រូវបានធ្វើឡើងសម្រាប់កាលបរិច្ឆេទតែមួយ ដែលអនុលោមទៅតាមគោលការណ៍ណែនាំរបស់ធនាគារជាតិ នៃ កម្ពុជា និង CAS លុះត្រាតែមានភ័ស្តុតាងជាក់ស្តែងបង្ហាញថាការប៉ាន់ស្មានទាំងនោះមានកំហុសឆ្គង។

- ការឈប់កត់ត្រាទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ៖ ធនាគារបានអនុវត្តតម្រូវការក្នុងការឈប់កត់ត្រារបស់ CIFRS 9 ក្នុងពេលអនាគត ចំពោះប្រតិបត្តិការទាំងឡាយណាដែលបានកើតឡើងនៅកាលបរិច្ឆេទប្តូរមកអនុវត្ត CIFRS ឬ កាលបរិច្ឆេទបន្ទាប់ពីនេះ (ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨)។

- ការធ្វើចំណាត់ថ្នាក់ និងការវាស់វែងទ្រព្យសកម្មហិរញ្ញវត្ថុ ៖ ទ្រព្យសកម្មហិរញ្ញវត្ថុរបស់ធនាគារ គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ត្រូវបានវាយតម្លៃធៀបនឹងចំណាត់ថ្នាក់សាកល្បង នៃគំរូអាជីវកម្ម និងការទូទាត់សងប្រាក់ដើម និងការប្រាក់ទាំងស្រុង (SPPI) អាស្រ័យទៅតាមអង្គហេតុ និងកាលៈទេសៈ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។

## ធនាគារ ឯកទេស ខេប៊ី ដេហាន ម.ក

## កំណត់សម្គាល់របាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ដំណាច់ឆ្នាំថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៩

### ៤. ការផ្ទេរមកអនុវត្ត CIFRS (ត)

<u>ការលើកលែងសំខាន់ៗដែលអាចអនុវត្តបានចំពោះធនាគារ (ត)</u>

- ការថយចុះតម្លៃនៃទ្រព្យសកម្មហិរញ្ញវត្ថុ ៖ ធនាគារបានអនុវត្តតម្រូវការសម្រាប់ការថយចុះតម្លៃរបស់ CIFRS 9ត្រឡប់ក្រោយ ដោយប្រើប្រាស់ព័ត៌មានសមហេតុផល និងព័ត៌មានដែលមានការគាំទ្រ និងដែលអាចរកបានដោយមិនចាំបាច់ត្រូវមានការចំណាយ និងការប្រឹងប្រែងហួសកម្រិត ដើម្បីកំណត់ហានិភ័យឥណទាននាកាលបរិច្ឆេទដែលឧបករណ៍ហិរញ្ញវត្ថុនោះត្រូវបានកត់ត្រាលើកដំបូង និងបានប្រៀបធៀបជាមួយនឹងហានិភ័យ ឥណទាននាកាលបរិច្ឆេទប្តូរមកអនុវត្ត CIFRS (ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨)។

<u>ការលើកលែងដែលអាចជ្រើសរើសបានដោយធនាគារ</u>

- ភតិសន្យា ៖ ធនាគារវាយតម្លៃកិច្ចសន្យាភតិសន្យាមួយ ទៅតាមមូលដ្ឋាននៃអង្គហេតុ និងកាលៈទេសៈដែលកើតមាននៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។ ធនាគារបានវាស់វែងបំណុលភតិសន្យានៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ តាមតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យា និងបានធ្វើអប្បហារដោយប្រើអត្រាកំណើនប្រាក់កម្ចី។ ទ្រព្យសកម្មដែលមានសិទ្ធិប្រើប្រាស់ ត្រូវបានកត់ត្រាតាមចំនួនទឹកប្រាក់ដែលស្មើនឹងបំណុលភតិសន្យា ហើយបូកបន្ថែមចំនួនទឹកប្រាក់ដែលបានបង់មុន ឬ ការទូទាត់ភតិសន្យាបង្គរ ពាក់ព័ន្ធនឹងភតិសន្យាដែលត្រូវបានកត់ត្រានៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុភ្លាមៗមុនថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។ គិតត្រឹមថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ មានភតិសន្យាមួយ (សម្រាប់ការជួលការិយាល័យចាស់) ដែលមានរយៈពេលនៅសល់បីខែទៀត ហើយធនាគារបានប្រើវិធីសាស្ត្រជាក់ស្តែងដែលត្រូវបានអនុញ្ញាតដោយស្តង់ដារដូចខាងក្រោម ដោយៈ

    - បានប្រើប្រាស់អត្រាអប្បហារតែមួយ សម្រាប់ portfolio ភតិសន្យាដែលមានលក្ខណៈស្រដៀងគ្នា ដោយគិតទៅលើរយៈពេលជួលដែលនៅសល់ ចំណាត់ថ្នាក់ទ្រព្យសកម្មមូលដ្ឋានប្រហាក់ប្រហែលគ្នា និងបំណុលភតិសន្យាប្រហាក់ប្រហែលគ្នា។
    - អនុវត្តការលើកលែងតម្លៃទាប ចំពោះភតិសន្យាទាំងឡាយណាដែលមានរយៈពេលនៅសល់១២ខែ ឬខ្លីជាងនេះ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ និង
    - បានប្រើប្រាស់ព័ត៌មានជាក់ស្តែងដែលបានកើតឡើង បន្ទាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ដើម្បីគាំទ្រដល់ការវាយតម្លៃរយៈពេលនៃភតិសន្យា ក្នុងករណីដែលមានជម្រើសក្នុងការបន្ត ឬ បញ្ឈប់រយៈពេលជួល ដែលពាក់ព័ន្ធនឹងការវិនិច្ឆ័យ នៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨។

- ការវាស់វែងតម្លៃសមស្របនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬ បំណុលហិរញ្ញវត្ថុ នាពេលកត់ត្រាលើកដំបូង ៖ ធនាគារបានអនុវត្តតម្រូវការក្នុងការកត់ត្រាចំណេញ-ខាតនៅ "ថ្ងៃទី១" របស់ CIFRS 9 ទៅថ្ងៃអនាគត ចំពោះប្រតិបត្តិការដែលបានកើតឡើងនៅថ្ងៃទី០១ ខែមករា ឆ្នាំ២០១៨ ឬបន្ទាប់ពីនេះ។

